១៤

# អំណាចខាងវិញ្ញាណ និង អំណាចនៃការអស្ចារ្យ

ការស្វែងរកឃើញអំណាចខាងវិញ្ញាណដ៏ពិតប្រាកដ និង ឥទ្ធិពលរបស់វា

## សៀវភៅសំរាប់សិស្ស

សិក្សាជាក្រុម

**សំរាប់**គ្រិស្តបរិស័ទថ្មី

# មាតិការ


**ជំពូកទី១ តួនាទីរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោករបស់យើង ..........................៣**

ក. តើអ្វីខ្លះ ដែលមនុស្សគិតអំពីព្រះជាម្ចាស់នៅសព្វថ្ងៃនេះ?....................................................៣

ខ. ព្រះជាម្ចាស់នៃពិភពទាំងមូល ..........................................................................................៤

គ. តើព្រះជាម្ចាស់គង់នៅជាមួយមនុស្សក្នុងសម័យព្រះគម្ពីរដោយរបៀបណា?..............................៥

ឃ. តើព្រះជាម្ចាស់ប្រើអំណាចនៃការអស្ចារ្យរបស់ទ្រង់ដោយរបៀបណា?...................................៦

ង. តើអ្វីជាផែនការរបស់ព្រះជាម្ចាស់សំរាប់ពេលអនាគត?......................................................៨

**ជំពូកទី២ ចរិកលក្ខណៈពីអំណាចនៃការអស្ចារ្យដ៏ពិត.......................................១០**

ក. ភាពពិតនៃការដែលចុះខ្សោយខាងវិញ្ញាណ...................................................................១០

ខ. តើមានន័យយ៉ាង ដែលថា ការធ្វើអោយខ្លាំងខាងវិញ្ញាណ?................................................១១

គ. កុំព្យាយាមយកតំរាប់តាមអំណាចរបស់ព្រះជាម្ចាស់...........................................................១៥

ឃ. ចំនុចគន្លឹះនៃពាក្យទាំង៤យ៉ាងចំពោះជីវិតនៃអំណាចខាងវិញ្ញាណ..........................................១៧

១. ការជឿ.......................................................................................................១៧

២. ការទុកចិត្ត...................................................................................................១៧

៣. សេចក្តីសង្ឃឹម...............................................................................................១៨

៤. ជំនឿ..........................................................................................................១៩

**ជំពូកទី៣ របៀបទទួលបានអំណាចខាងវិញ្ញាណ...........................................២៥**

ក. កុំព្យាយាមស្វែងរកអោយបានធ្វើដារាខាងវិញ្ញាណ.........................................................២៥

ខ. វាត្រូវការចំណាយពេលច្រើនបន្តិច និង ធ្វើការដើម្បីអភិវឌ្ឍអំណាចខាងវិញ្ញាណ....................២៧

គ. ជំហានជាមូលដ្ឋានក្នុងការអភិវឌ្ឍន៏អំណាចខាងវិញ្ញាណ.....................................................២៩

**ជំពូកទី៤ អំណាចខាងវិញ្ញាណដ៏ពិតទល់នឹងអំណាចនៃការក្លែងបន្លំ.......................៣៣**

ក. អំណាចរបស់ព្រះជាម្ចាស់ ទល់នឹង អំណាចរបស់មារសាតាំង ទល់នឹង អំណាចមនុស្ស...............៣៣

ខ. ជំនឿ ទល់នឹង ការសន្និដ្ឋាន.........................................................................................៣៩

គ. កំហុសឆ្គងនៅក្នុងជំនឿពីការបង្រៀននៅសព្វថ្ងៃនេះ........................................................៤២

# ជំពូកទី១
# តួនាទីរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោករបស់យើង

## ក. តើអ្វីខ្លះ ដែលមនុស្សគិតអំពីព្រះជាម្ចាស់នៅសព្វថ្ងៃនេះ?

មានមនុស្សជាច្រើនមិនបានចំណាយពេលផ្ទាល់ខ្លួន ដើម្បីចង់ស្គាល់ព្រះអង្គទេ ។ ដូច្នេះវាមិនមែនជាការគួរអោយភ្ញាក់ផ្អើលទេ ដែលថាមានពេលជាច្រើន ពួកគេមានគំនិតខុសឆ្គងមួយចំនួនអំពីព្រះជាម្ចាស់ថា ទ្រង់គឺជានរណា ។ ព្រះជាម្ចាស់មិនមែនគ្រាន់តែអង្គុយនៅលើបល្ល័ងនៅស្ថានសួគ៌ដោយមានកាន់រំពាត់ ហើយរងចាំវ៉ៃយើង នៅពេលណាដែលយើងដើរខុសគន្លងនោះទេ ។ ទ្រង់មិនមែនជាព្រះដែលពេញទៅដោយកំហឹងនោះទេ ។ ទ្រង់គឺជាព្រះជាម្ចាស់នៃសេចក្តីស្រលាញ់ និង ចិត្តអត់ឣត់ ។ ជាការពិតណាស់ ទ្រង់មានព្រះទ័យក្រៀមក្រំ នៅពេលដែលយើងប្រព្រឹត្តអំពើបាប ។ ប៉ុន្តែទ្រង់មិនដែលស្វែងរកឱកាសក្នុងថ្ងៃនីមួយៗ ដើម្បីស្វែងរកកំហុសរបស់យើងហើយដាក់ទោសនោះទេ ទ្រង់ដឹងថាយើងជាមនុស្សដែលមិនមែនល្អឥតខ្ចោះទេ ។ ប្រសិនបើ ព្រះជាម្ចាស់គ្មានចិត្តអត់ឣត់ រឺក៏ សេចក្តីមេត្តាករុណាទេ នោះយើងទាំងអស់គ្នាមុខជាស្លាប់ជាមិនខាន ។

មានមនុស្សមួយចំនួនមើលទៅព្រះជាម្ចាស់នៅក្នុងផ្លូវផ្ទុយមួយផ្សេងទៀត ។ "ប្រសិនបើមានព្រះជាម្ចាស់មួយអង្គមែន" ពួកគេនិយាយថា "ជាការពិតណាស់ ទ្រង់មិនខ្វល់ខ្វាយខ្លាំងណាស់ណា អំពីអ្វីដែលកំពុងតែកើតឡើងនៅលើផែនដីនាពេលសព្វថ្ងៃនេះទេ ។ សូមមើលពី ភាពអំពើអយុត្តិធម៌នានា ភាពអត់ឃ្លាន ភាពក្រីក្រ និង សង្គ្រាម ។ ប្រសិនបើ ព្រះជាម្ចាស់ពិតជាបានបង្កើតពិភពលោកនេះមែន នោះទ្រង់បោះបង់ចោលយើងកាលពីគ្រាដំបូងមកម្លោះ

អ្នកមិនអាចជំនឿបែបនេះ ហើយនៅពេលតែមួយជឿលើព្រះគម្ពីរដ៏ពិតបាននោះទេ ។ ព្រះជាម្ចាស់មិនបានបង្កើតពិភពលោកនេះមក ហើយនិយាយថា "ឥឡូវនេះ សូមអ្នកចាត់ចែងដោយឯងផ្ទាល់ទៅ ហើយបើមានបញ្ហាណាមួយមិនត្រូវមករកយើងនោះទេ" ព្រះជាម្ចាស់មិននៅស្ងៀមនោះទេ ។ ទ្រង់ពិតជាខ្វល់ខ្វាយពីអ្នក និង គ្រប់មនុស្សទាំងអស់ទៀត ។

ពាក្យសំដីរបស់មនុស្សមួយក្រុមនិយាយថា "អនាគតរបស់យើងត្រូវបានសំរេចរួចរាល់អស់ហើយ" "ព្រះជាម្ចាស់ដឹងគ្រប់ការទាំងអស់ ។ ទ្រង់គ្រប់គ្រងលើអ្វីៗទាំងអស់ ។ យើងគ្រាន់តែជាតុក្កតានៅលើខ្សែររបស់ទ្រង់ប៉ុណ្ណោះ ។

ដូច្នេះហើយមិនចាំបាច់ព្យាយាមបំផ្លាស់បំប្រែនោះទេ ។ ប្រសិនបើ ព្រះជាម្ចាស់ពិតជាចង់អោយខ្ញុំផ្លាស់ប្រែ ទ្រង់អាចធ្វើកិច្ចការនោះបាន ។" សេចក្តីពិតដ៏ពិប្រាកដនោះគឺថា យើងទាំងអស់គ្នាមិនមែនតុក្កតាទេ ។ ព្រះជាម្ចាស់បានបង្កើតយើងទាំងអស់គ្នាមកអោយមានសេរីភាពក្នុងការជ្រើសរើស ។ ទ្រង់នឹងគ្រាន់តែបង្ហាញពីឥទ្ធិពល និង ប្រាប់ដល់យើងប៉ុណ្ណោះ ប៉ុន្តែទ្រង់នឹងមិនបង្ខំយើងដើម្បីអោយដើរតាមទ្រង់នោះទេ ។

## ខ. ព្រះជាម្ចាស់នៃពិភពទាំងមូល

ព្រះគម្ពីរប្រទានអោយយើងនូវរូបភាពមួយដ៏ច្បាស់លាស់នៃតួនាទីរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោករបស់យើង ។ កណ្ឌគម្ពីរដំបូងបង្អស់នៅក្នុងព្រះគម្ពីរប្រាប់យើងពីរបៀបដែលព្រះជាម្ចាស់បានបង្កើតសកលលោកទាំងមូល — ព្រះអាទិត្យ, ព្រះចន្ទ, ដួងដារា, រុក្ខជាតិ និង សព្វបក្សាបក្សីនានា ។ ព្រះជាម្ចាស់បានមានបន្ទូល នោះអ្វីៗទាំងអស់ក៏កើតមានឡើង ។ ទ្រង់បានប្រទានជីវិតដល់ លោកអដាំ និង នាងអេវ៉ា ក្រោយពីបង្កើតរូបកាយពួកគេទាំងពីរចេញពីធូលីដី ។ គ្រប់សកម្មភាពនៃការបង្កើតរបស់ទ្រង់ គឺបង្ហាញពីព្រឹត្តិការណ៍នៃអំណាចដ៏អស្ចារ្យ ។

ព្រះជាម្ចាស់បានបង្កើតមនុស្សអោយមានសមត្ថភាពពិសេស — គឺឆន្ទៈសេរី ។ មនុស្សមានសមត្ថភាពជ្រើសរើស, ធ្វើការសំរេចចិត្តផ្ទាល់ខ្លួន ។ យើងអាចជ្រើសរើសដើរតាមព្រះជាម្ចាស់ រឺក៏ មារសាតាំង ។ សមត្ថភាពនេះក្នុងការជ្រើសរើសគឺមានការទាក់ទងយ៉ាងផ្ទាល់ទៅនឹងអំពើបាបនៅក្នុងពិភពលោករបស់យើង ។ យើងទាំងអស់គ្នានឹងជួបការល្បួងនានាអោយប្រព្រឹត្តអំពើបាប ។ ជារៀងរាល់ពេល ថាតើ យើងជ្រើសរើសតទល់នឹងសេចក្តីល្បួងទាំងនោះ រឺក៏ចុះចូលនឹងវា ។ យើងទទួលខុសត្រូវទៅនឹងជំរើសដែលយើងជ្រើសរើស ។ យើងមិនអាចស្តីបន្ទោសមនុស្សផ្សេងទៀត ព្រះជាម្ចាស់ រឺក៏ មារសាតាំងសំរាប់ការសំរេចចិត្តទាំងអស់នេះទេ ។ ព្រះជាម្ចាស់បានបង្កើតយើងអោយមានសមត្ថភាពដើម្បីធ្វើការជ្រើសរើសរវាងភាពត្រឹមត្រូវ រឺក៏ ការខុសឆ្គង ។

### ច្បាប់នៃធម្មជាតិ

នៅពេលព្រះជាម្ចាស់បានបង្កើតពិភពលោករបស់យើងមក ទ្រង់បានកំណត់រួចជាស្រេចនូវសកម្មភាពមួយចំនួនចូលទៅក្នុង "ច្បាប់នៃធម្មជាតិ" ។ គ្រប់អ្វីៗដែលទ្រង់បានបង្កើតមកត្រូវរស់នៅក្នុងច្បាប់ទាំងនេះ ។ នៅពេលដែលយើងរំលោភច្បាប់នៃធម្មជាតិនេះ យើងនឹងប្រាកដជាទទួលរងគ្រោះជាមិនខាន ។

ប្រសិនបើ អ្នកបោះផ្កាដោយចៃដន្យក្តី រឺក៏ ដោយមានបំណងក្តី នោះផ្កានោះមុខធ្លាក់បែកជាមិនខាន ។ ច្បាប់នៃទំនាញផែនដី ដែលធ្វើអោយផ្កានោះធ្លាក់បែក ។ ច្បាប់នៃទំនាញផែនដី ហើយ ច្បាប់ផ្សេងទៀតនៃធម្មជាតិ គឺមានភាពពឹងផ្អែកគ្នាទៅវិញទៅមក ។ ប្រសិនបើ អ្នកទំលាក់អ្វីមួយ វាតែងតែធ្លាក់ទៅដី មិនមែនធ្លាក់ទៅឡើងលើ រឺ អណ្តែតនោះទេ ។

ប្រសិនបើ អ្នកបើកឡានរបស់អ្នកជាន់លើដែកគោលដ៏មុតស្រួច នោះកង់ឡានមុខជាធ្លាយមិនខាន ។ ច្បាប់នៃធម្មជាតិមានប្រសិទ្ធិភាពនៅក្នុងស្ថានភាពនោះតែម្តង ។ ប្រសិនបើ អ្នកឈប់ផឹកសារធាតុរាវនៅថ្ងៃដែលក្តៅ នោះ អ្នកមុខជាស្រេចទឹកជាមិនខានក្រោយពីពេល ពីរទៅបីម៉ោង ។

មានឧទហរណ៏រាប់រយទៀត ដែលនិយាយអំពីច្បាប់នៃធម្មជាតិ និង របៀបដែលច្បាប់នោះជះឥទ្ធិពលមកលើ យើង ។ នៅពេលអ្នកក្លាយជាគ្រីស្ទបរិសទ័ អ្នកក៏នៅតែស្ថិតនៅក្រោមច្បាប់នៃធម្មជាតិនោះដែរ ។ យើងមិនអាចរំពឹង ព្រះជាម្ចាស់អនុញ្ញាត្តិអោយយើង ញែកចេញពីច្បាប់នៃធម្មជាតិពីយើង ដោយសារតែយើងជាគ្រីស្ទបរិសទ័នោះទេ ។

## គ. តើព្រះជាម្ចាស់គង់នៅជាមួយមនុស្សក្នុងសម័យព្រះគម្ពីរដោយរបៀបណា?

ប្រសិនបើ យើងមានឆន្ទៈទទួលយកព្រះគម្ពីរថាជា សេចក្តីពិត នោះយើងអាចមើលឃើញឧទាហរណ៏ជាច្រើន ពីរបៀបដែលព្រះជាម្ចាស់មានការខ្វល់ខ្វាយជាខ្លាំងដល់មនុស្សជាច្រើន ។ គម្ពីរសញ្ញាចាស់ពោរពេញទៅដោយសាច់ រឿងជាច្រើន ដែលបានបង្ហាញពីសេចក្តីស្រលាញ់ និង សេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់សំរាប់ប្រជាជាតិអ៊ីស្រា អែល ។

ព្រះគម្ពីរផ្ទាល់គឺជាគំរូពីរបៀបដែលព្រះជាម្ចាស់ សំដែងជាតួអង្គដ៏សំខាន់នៅក្នុងពិភពលោកយើងនេះ ។ ព្រះគម្ពីរប្រកាសថាជា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនមែនគ្រាន់តែជាសៀវភៅសាសនាមួយក្នុងចំណោមសាសនា នានានោះទេ ។ ព្រះជាម្ចាស់បានចងក្រងសៀវភៅនេះឡើងដើម្បីជាប្រយោជន៏សំរាប់យើងទាំងអស់គ្នា ។ តើហេតុអ្វី? ដោយព្រោះទ្រង់ស្រលាញ់យើង ហើយទ្រង់ពិតជាខ្វល់ខ្វាយអំពីអ្វីដែលកើតឡើងចំពោះយើង ។ ព្រះគម្ពីរពោរពេញ ទៅដោយក្រិត្យវិន័យរបស់ព្រះជាម្ចាស់សំរាប់មនុស្សលោក ។ ប្រសិនបើ យើងដើរតាមក្រិត្យវិន័យរបស់ទ្រង់ នោះ យើងមុខជានឹងមានបទពិសោធន៏ពីជីវិតដែលលើកទឹកចិត្ត និង ស្កប់ចិត្ត ។

នៅពេលព្រះយេស៊ូបានយាងចុះមកលើផែនដីនេះ ទ្រង់បានប្រទាននូវឧទាហរណ៍ផ្ទាល់ខ្លួនដ៏ចំបងពីរបៀប ដែលព្រះជាម្ចាស់ជាប់ទាក់ទងនៅក្នុងពិភពលោកនេះ ។ ទ្រង់បានរស់នៅក្នុងចំណោមមនុស្សជាច្រើន និង មនុស្សដែលត្រូវបានជិះជាន់ ។ ទ្រង់បានស្រលាញ់អ្នកមានបាប ប្រោសអ្នកជំងឺអោយបានជា ហើយទីបញ្ចាប់ទ្រង់សុគតសំរាប់អំពើបាបគ្រប់មនុស្សទាំងអស់ ។

មុនពេលសុគតរបស់ទ្រង់ ព្រះយេស៊ូបានសន្យាថា បញ្ជូនព្រះវិញ្ញាណដ៏វិសុទ្ធអោយគង់នៅជាមួយគ្រីស្ទបរិសទ័ ។ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាតួអង្គព្រះ ហើយសព្វថ្ងៃនេះ ទ្រង់គង់នៅជាប់ជាមួយយើងយ៉ាងស្និតស្នាលនៅក្នុងជីវិតរបស់យើងដើរតួនាទីជា គ្រូបង្រៀន ជាអ្នកដឹកនាំ ជាអ្នកជំនួយ ជាអ្នកកំសាន្តចិត្ត និង ជាអ្នកបង្ហាញពីអំពើបាបរបស់យើង ។

## ឃ. តើព្រះជាម្ចាស់ប្រើអំណាចនៃការអស្ចារ្យរបស់ទ្រង់ដោយរបៀបណា?

ព្រះជាម្ចាស់បានសំដែងអំណាចនៃការអស្ចារ្យរបស់ទ្រង់ ជាច្រើនដងចាប់តាំងពីការករកើតពិភពលោកមកម្លោះ ។ សកម្មភាពនៃការអស្ចារ្យរបស់ទ្រង់ តែងតែបង្ហាញពីអត្តចរិកដ៏ពិតប្រាកដរបស់ទ្រង់ ។ ទ្រង់មិនដែលបាត់ការគ្រប់គ្រងលើអារម្មណ៏របស់ទ្រង់ ហើយព្រះពិរោធ៏ចង់បំផ្លាញទីក្រុង រឺ ប្រជាជាតិណាមួយអោយចេញពីផែនដីនោះទេ ។ ការអស្ចារ្យរបស់ទ្រង់ជាច្រើនគឺស្តីពីតែពីការព្យាបាល រឺក៏ ការពារមនុស្ស ។

ព្រះជាម្ចាស់បានបើកផ្លូវមួយឆ្លងកាត់សមុទ្រក្រហម ដូច្នេះជនជាតិយូដាអាចរត់គេចពីប្រទេសអេស៊ីព និង កងទព័របស់ស្តេចផារ៉ោន ។ ទ្រង់បានការពារលោក ដានីញ៉ែល នៅពេលដែលគាត់ត្រូវបានគេដោះទៅក្នុងរោងសឹងជាមួយនឹងសត្វសឹងដ៏ស្រេកឃ្លាន ។ ព្រះជាម្ចាស់បានការពារ សាឌ្រាក់ មេសាក់ និង អរបេឌេកកោរ នៅពេលដែលពួកគេត្រូវបានគេដោះចូលទៅក្នុងឡដុតកំដៅ ។ ភ្លើងមិនបានធ្វើទុក្ខពួកគេនោះទេ ។ ជាពិតណាស់ នៅពេលដែលពួកគេបានចេញពីឡដុតដ៏ក្តៅនោះ សូម្បីតែសំលៀកបំពាក់របស់ពួកគេក៏មិនបានធំក្លិនអ្វីទាំងអស់ ។

ព្រះជន្មរបស់ព្រះយេស៊ូពោរពេញទៅដោយអំណាចនៃការអស្ចារ្យជាច្រើន ។ ព្រះយេស៊ូបានព្យាបាលមនុស្សខ្វាក់ ដេញខ្មោចចេញពីមនុស្ស ព្យាបាលមនុស្សកើតឃ្លង់ និង ប្រោសឡាសាអោយរស់ឡើងពីសេចក្តីស្លាប់ ។

### ១. អំណាចនៃអស្ចារ្យដ៏ធំបំផុតជាងពេលណាៗទាំងអស់

ព្រឹត្តិការណ៍ដ៏អស្ចារ្យបំផុតរបស់ព្រះជាម្ចាស់គឺជាផ្លូវមួយ ដែលទ្រង់បានប្រទានអោយយើងនូវការសង្គ្រោះអោយចេញពីអំពើបាបរបស់យើង ។ រ៉ូម ៦:២៣ ចែងថា ថ្លៃឈ្នួលនៃអំពើបាបគឺជាសេចក្តីស្លាប់ ។ រ៉ូម ៣:២៣ ចែងថា គ្រប់មនុស្សទាំងអស់សុទ្ធតែមានអំពើបាប ។ លុះត្រាតែ ព្រះជាម្ចាស់ប្រទានផ្លូវមួយនៃការសង្គ្រោះដល់យើងទាំងអស់គ្នា ទើបយើងទាំងអស់គ្នាមិនត្រូវទៅបឹងភ្លើងដោយព្រោះតែអំពើបាបរបស់យើងនោះទេ ។

ប៉ុន្តែព្រះជាម្ចាស់អង្គទ្រង់ផ្ទាល់បានយាងមកលើផែនដីនេះ ដើម្បីរស់នៅក្នុងចំណោមយើង ហើយបានសុគតសំរាប់អំពើបាបយើងថែមទៀតផង ។ គ្មានការអស្ចារ្យណាមួយប្រសើរជាងការអស្ចារ្យដែលស្តីពីការសុគតរបស់ព្រះយេស៊ូនោះទេ ។ ទ្រង់គឺជាព្រះជាម្ចាស់ ប៉ុន្តែទ្រង់បានបោះបង់ចោលគ្រប់ទាំងអំណាចរបស់ទ្រង់ មុនពេលទ្រង់បានយកជាមនុស្ស ។ នៅពេលដែលព្រះយេស៊ូត្រូវបានគេឆ្កាងនៅលើឈើឆ្កាង ទ្រង់មានអារម្មណ៍ឈឺចុកចាប់ដូចជាមនុស្សដ៏ទៃទៀតផងដែរ ។ ភាពឈឺចាប់ដែលកើតចេញពីអំពើបាបរបស់មនុស្ស ត្រូវបានធ្លាក់មកលើព្រះយេស៊ូ ដោយគេបានឆ្កាងទ្រង់នៅលើឈើឆ្កាង ។ ការសុគតរបស់ទ្រង់ពិតជាបានកើតឡើងមែន ។

បីថ្ងៃក្រោយមកយើងមើលពីអំណាចនៃការអស្ចារ្យរបស់ទ្រង់ ។ ព្រះយេស៊ូត្រូវបានប្រោសអោយមានព្រះជន្មរស់ឡើងវិញពីការសុគតរបស់ទ្រង់ ។ ទណ្ឌកម្មដ៏ពិតប្រាកដសំរាប់អំពើបាបរបស់យើងគឺត្រូវបានបង់ថ្លៃជំនួសហើយ ។ សេចក្តីសង្ឃឹមនៃជីវិតអស់កល្បជានិច្ចសំរាប់មនុស្សលោក គឺត្រូវបានបង្ហាញយ៉ាងច្បាស់សំរាប់ពួកគេ ។ ដោយព្រោះទ្រង់រស់ យើងអាចមានបទពិសោធន៏នូវការលើកលែងទោសពីអំពើបាបរបស់យើង ហើយរស់នៅក្នុងជីវិត ដែលមានសេចក្តីសង្ឃឹមក្រោយពីយើងស្លាប់ទៅ ។ ចំនុចគន្លឹះដែលអាចអោយយើងមានបទពិសោធន៏នូវជីវិតអស់កល្បជានិច្ចគឺការដ៏សាមញ្ញបំផុត ។ នៅថ្ងៃនេះ យើងត្រូវទទួលយកការទទួលសង្គ្រោះ ដែលទ្រង់ប្រទានអោយ ។ រ៉ូម ៨:១១ ចែងថា "ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រោសព្រះយេស៊ូអោយរស់ឡើងវិញ ។ ប្រសិនបើ ព្រះវិញ្ញាណដ៏វិសុទ្ធដដែលគង់នៅក្នុងអ្នក នោះទ្រង់នឹងប្រទានជីវិតនៅក្នុងរូបកាយរបស់អ្នកនៅក្នុងវិធីដដែល ។"

ការសង្គ្រោះសំរាប់គ្រប់មនុស្សម្នាក់ៗគឺជាសកម្មភាពនៃអំណាចដ៏អស្ចារ្យ ។ គ្មាននរណាម្នាក់អាចទទួលបានការសង្គ្រោះដោយការខិតខំរបស់មនុស្សនោះទេ ។ ការសង្គ្រោះគឺជាអំណោយទានមកពីព្រះជាម្ចាស់ ។ ការអស្ចារ្យនោះនៃជីវិតថ្មីគឺមានសំរាប់គ្រប់មនុស្សទាំងអស់ ។

## ២. យើងត្រូវការអំណាចខាងវិញ្ញាណដើម្បីបន្តដើរក្នុងជំនឿជាគ្រីស្ទបរិស័ទ

ការសង្គ្រោះគឺជាកំណើតខាងវិញ្ញាណ ។ ជារឿយៗ យើងហៅវាថា ការកើតជាថ្មី ។ កំណើតខាងវិញ្ញាណគឺជាការអស្ចារ្យ -- មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចអោយជីវិតនេះមកយើងបាន ។ ប៉ុន្តែដើម្បីបន្តរស់នៅសំរាប់ព្រះគ្រីស្ទគឺជាការជំរុញដ៏លំបាកមួយ ។ ប្រសិនបើ អ្នកគ្មានជំនួយរបស់ព្រះជាម្ចាស់ទេ នោះអ្នកនឹងមិនអាចសំរេចវាបានឡើយ ។ យើងទាំងអស់គ្នាត្រូវការអំណាចរបស់ព្រះជាម្ចាស់ជាប្រចាំថ្ងៃ ដើម្បីរស់នៅក្នុងជីវិតជាគ្រីស្ទបរិសទ័ដែលស្មោះត្រង់ ។ នៅក្នុងគម្ពីររ៉ូម ៦ និង ៧ លោកប៉ូល បានពិពណ៌នាថា អំណាចនៃអំពើបាប និង ទំលាប់ចាស់ និង ចិត្តស្រើបស្រាលនានាបានជះឥទ្ធិពលមកលើជីវិតរបស់គាត់ ។ គាត់និយាយថា សង្គ្រាមមានការវិបាកណាស់ក្នុងការប្រយុទ្ធប្រឆាំងតនឹងវាដោយកំលាំងរបស់គាត់ផ្ទាល់ ។ បើមើលនៅក្នុងគម្ពីររ៉ូមជំពូក៨ពីដើមមក គាត់ប្រាប់ពីវិធីអោយមានសេរីភាពចេញពីអំណាចនៃអំពើបាប ។

**រ៉ូម ៨:២**
**ដ្បិតវិន័យរបស់ព្រះវិញ្ញាណដែលផ្តល់ជីវិតក្នុងអង្គព្រះយេស៊ូគ្រិស្ត បានរំដោះខ្ញុំអោយរួចផុតពីបាប និង ពីសេចក្តីស្លាប់ ។**

យើងមានព្រះបន្ទូលសន្យាដែលថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងគង់នៅជាមួយយើង ហើយចាំជួយយើង ។ ទ្រង់នឹងមិនបង្ខំជំនួយរបស់ទ្រង់មកលើយើងនោះទេ ប៉ុន្តែប្រសិនបើយើងទូលសូមទ្រង់អោយជួយ នោះសព្វព្រះទ័យនឹងជួយយើងជាមិនខាន ។ នៅពេលដែលយើងមានភាពចាស់ទុំនៅក្នុងទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ នោះយើងនឹងមានកំលាំងខ្លាំងខាងវិញ្ញាណ ។

## ង. តើអ្វីជាផែនការរបស់ព្រះជាម្ចាស់សំរាប់ពេលអនាគត?

ព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ថា ព្រះជាម្ចាស់មិនទាន់បញ្ចប់សព្វគ្រប់ជាមួយនឹងសកម្មភាពនៃអំណាចដ៏អស្ចារ្យរបស់ទ្រង់នៅឡើយទេ ។ ព្រះយេស៊ូបានសន្យាថា នឹងយាងត្រឡប់មកវិញម្តងទៀតនៅលើផែនដីនេះជាមួយនឹងអ្នកជឿដ៏ពិតប្រាកដរបស់ទ្រង់ ហើយរៀបចំនគររបស់ទ្រង់នៅលើផែនដីនេះ ។ ព្រឹត្តិការណ៏ដ៏អស្ចារ្យមួយចំនួននឹងកើតមានឡើង ។ ចំនុចមួយគឺថា នឹងមានការរស់ឡើងវិញពីគ្រប់គ្រីស្ទបរិសទ័ទាំងអស់ ដែលមានជំនឿដ៏ពិតប្រាកដ ។ គ្រប់ទាំងអំណាច និង កងកំលាំងរបស់ពួកគេវិញ្ញាណអាក្រក់នឹងត្រូវបានបំផ្លាញ ។

នៅក្នុងកណ្ឌ័គម្ពីរចុងក្រោយគឺ គម្ពីរវិវរណៈ ប្រាប់ពីពេលវេលានៅថ្ងៃអនាគត នៅពេលណា ដែលព្រះជាម្ចាស់នឹងបំផ្លាញស្ថានសួគ៌ និង ផែនដីបច្ចុប្បន្ននេះចោល ហើយទ្រង់បង្កើតថ្មីមួយឡើង ។ ព្រះជាម្ចាស់នៅតែបន្ត និង ទាក់ទងទៅនឹងពិភពលោករបស់យើងយ៉ាងជិតស្និត ។ ទ្រង់ពិតជាខ្វល់ខ្វាយនូវអ្វីដែលកើតឡើងនៅក្នុងជីវិតរបស់អ្នក និងប្រទានអំណាចរបស់ទ្រង់ដើម្បីជួយអ្នកអោយអាចយកឈ្នះ លើសង្គ្រាមខាងវិញ្ញាណ ហើយឈរនៅពីមុខអ្នក ។

# ជំពូកទី២
# ចរិកលក្ខណៈពីអំណាចនៃការអស្ចារ្យដ៏ពិត

## ក. ភាពពិតនៃការដែលចុះខ្សោយខាងវិញ្ញាណ

ប្រសិនបើអ្នកបានសំរេចចិត្តក្លាយជាគ្រិស្តបរិសទ័ នោះអ្នកត្រូវដឹងថា វាមិនមែនជាការងាយស្រួលក្នុងការបន្តរស់នៅអោយបានស្មោះត្រង់បំផុតចំពោះព្រះយេស៊ូគ្រិស្តទេ ។ ចាំបន្តិច -- ពិតជាមានច្រើនជាងនេះទៀត! ប្រសិនបើអ្នកព្យាយាមរស់អោយបានស្មោះត្រង់ចំពោះព្រះយេស៊ូគ្រិស្តដោយកំលាំងរបស់អ្នកផ្ទាល់ នោះអ្នកនឹងទទួលបរាជ័យនៅក្នុងពេលភ្លាម១ រឺក៏ ក្រោយមកទៀតជាក់ជាមិនខាន ។ យើងត្រូវតែមានអំណាចមកពីព្រះជាម្ចាស់ដើម្បីអោយមានភាពស្មោះត្រង់នៅចំពោះទ្រង់ ។ ទ្រង់បានសន្យាថា ទ្រង់នឹងគង់នៅជាមួយយើង ដើម្បីជួយយើង និង ណែនាំយើង ។ យើងទាំងអស់គ្នាមានចំនុចខ្សោយនៅខាងក្នុង ។ ការល្បួងនានាដែលនៅជុំវិញយើងមានកំលាំងខ្លាំងជាងយើង ។

លោក សាវក័ប៉ូលគឺជាបេសកជនម្នាក់ក្នុងចំណោមបេសកជនដ៏អស្ចារ្យជាច្រើនជាងពេលណា១ទៅទៀត គឺជាមនុស្សដែលពេញទៅដោយកំលាំងខាងវិញ្ញាណ ។ ក៏ប៉ុន្តែគាត់នៅតែទទួលសារភាពថា គាត់នូវមានចំនុចខ្សោយជាច្រើនខាងវិញ្ញាណ ។ នៅក្នុងករណីរបស់លោកប៉ូល ព្រះជាម្ចាស់បានអនុញ្ញាត្តិអោយបញ្ហាចូលក្នុងជីវិតរបស់គាត់ ដើម្បីធានាថា គាត់នៅតែនឹកចាំ និង ពឹងផ្អែកលើព្រះជាម្ចាស់គ្រប់ពេលវេលាជានិច្ច ។ លោកប៉ូល បានសូមទៅព្រះជាម្ចាស់ដល់ទៅបីដង សូមអោយទ្រង់យកបញ្ហាចេញពីជីវិតរបស់គាត់ ប៉ុន្តែព្រះជាម្ចាស់និយាយថា "ទេ" ។

**២កូរិនថូស ១២:៩-១០**

**ក៏ប៉ុន្តែព្រះអង្គមានបន្ទូលមកខ្ញុំថា "ព្រះគុណរបស់យើងបានផ្តល់មកល្មមគ្រប់គ្រាន់សំរាប់អ្នកហើយ ដ្បិតឫទ្ធានុភាពរបស់យើងនឹងលេចចេញមកយ៉ាងខ្លាំងបំផុតក្នុងមនុស្សទន់ខ្សោយ" ។ ដូច្នេះខ្ញុំចូលចិត្តអួតខ្លួនអំពីភាពទន់ខ្សោយរបស់ខ្ញុំជាង ដើម្បីអោយឫទ្ធានុភាពរបស់ព្រះគ្រិស្តមកសណ្ឋិតលើខ្ញុំ ។ ហេតុនេះព្រោះតែព្រះគ្រិស្ត ខ្ញុំអរសប្បាយនៅពេលទន់ខ្សោយ នៅពេលគេជេរប្រមាថ នៅពេលខ្វះខាត នៅពេលគេបៀតបៀន នៅពេលតប់ប្រមល់ ដ្បិតពេលណាខ្ញុំទន់ខ្សោយ គឺពេលនោះហើយដែលខ្ញុំមានកំលាំង ។**

យើងនឹងតែងតែពឹងផ្អែកលើព្រះជាម្ចាស់ ដើម្បីអោយទ្រង់ជួយយើង ។ លោកប៉ូល គឺជាមនុស្សម្នាក់ឆ្លាតវៃ មានចំណោះដឹងខ្ពង់ខ្ពស់ ហើយក៏ជាអ្នកដឹកនាំដ៏ខ្លាំងពូកែទៀតផង ។ ក៏ប៉ុន្តែលោកមិនដែលបានទៅដល់គោលដៅដែលគាត់ត្រូវនិយាយថា "ឥឡូវនេះខ្ញុំមានកំលាំងខ្លាំងខាងវិញ្ញាណហើយ ព្រមទាំងចាស់ទុំទៀតផង ដូច្នេះខ្ញុំមិនចាំបាច់ពឹងផ្អែកលើព្រះជាម្ចាស់ដើម្បីអោយទ្រង់ជួយខ្ញុំទៀតទេ ។" យើងមិនត្រូវមានការភ័យខ្លាចចំពោះភាពកំសោយរបស់យើងនោះទេ ។ ប៉ុន្តែយើងត្រូវមានភាពស្មោះត្រង់អំពើតម្រូវការរបស់យើង ដើម្បីសុំជំនួយពីព្រះជាម្ចាស់ ។ យើងអាចសំឡឹងទៅព្រះជាម្ចាស់ដោយទំនុកចិត្តដើម្បីអោយព្រះអង្គជួយ ។ ទ្រង់បានប្រាប់ដល់លោកប៉ូលថា "យើងគង់នៅជាមួយអ្នក គឺគ្រប់ទាំងតម្រូវការរបស់អ្នក ។" ព្រះបន្ទូលដដែលមកពីព្រះជាម្ចាស់នោះ ក៏ជាព្រះបន្ទូលពិតសំរាប់យើងម្នាក់ៗផងដែរ ។ យើងទាំងអស់គ្នាខ្សោយ ប៉ុន្តែព្រះជាម្ចាស់គង់នៅជាមួយយើង ។

## ខ. តើមានន័យយ៉ាង ដែលថា ការធ្វើអោយខ្លាំងខាងវិញ្ញាណ?

មានវិធីជាច្រើន ដើម្បីពិពណ៌នាពីអំណាចនេះដែលថា ព្រះជាម្ចាស់ចង់អោយគ្រប់គ្រិស្តបរិសទ័ទាំងអស់មាន ។

### ១. អ្នកបានធ្វើការសំរេចចិត្តមែនទែនដើម្បីរស់នៅសំរាប់ព្រះគ្រិស្តយេស៊ូ

មនុស្សដែលខ្លាំងខាងវិញ្ញាណបានធ្វើការសំរេចចិត្តយ៉ាងច្បាស់លាស់ដើម្បីបំរើព្រះយេស៊ូគ្រិស្ត ។ ការសំរេចចិត្តនេះគឺមានសារៈសំខាន់ខ្លាំងជាងការក្លាយជាមិត្តភ័ក្តិ ជាងលុកកាក់ រឺក៏ ជោគជ័យផ្សេងទៀត ។ គាត់សុខចិត្ត ប្រសិនបើចាំបាច់សុគតមុនពេល បដិសេធន៏ព្រះយេស៊ូគ្រិស្ត ។ សូមរងចាំមួយភ្លែតសិន អ្នកនិយាយថា ខ្ញុំស្រលាញ់ព្រះយេស៊ូ ប៉ុន្តែតើខ្ញុំចាំបាច់ស្លាប់ ដើម្បីបង្ហាញថា ខ្ញុំមានជំនឿដ៏រឹងមាំលើព្រះយេស៊ូគ្រិស្តឬ? ទេ ។ ប៉ុន្តែអស់អ្នកណាដែលខ្លាំងខាងវិញ្ញាណមានធ្វើការសំរេចចិត្តដោយឥតងាករេចំពោះព្រះគ្រិស្តយេស៊ូ ។

មានគ្រិស្តបរិសទ័មួយចំនួនខ្លះសុខចិត្តរស់នៅដើម្បីព្រះយេស៊ូ ដរាបណាដែលជីវិតរស់នៅយ៉ាងរលូនដោយពុំមានបញ្ហាធ្ងន់ធ្ងរកើតឡើង ។ នៅថ្ងៃអាទិត្យគាត់នៅក្នុងព្រះវិហារ ហើយ អធិស្ឋាន ។ ប៉ុន្តែថ្ងៃអង្គារ៏គាត់ជាមនុស្សម្នាក់ផ្សេងទៀត ។

គាត់មានបញ្ហាជាច្រើន ហើយ ឥឡូវនេះគាត់កំពុងតែជេរដាក់បណ្តសសារ និង ស៊ីធឹកទៅវិញ ។ គាត់គ្មានបំណងចង់អោយគេដឹងថា ជាគ្រិស្តបរិសទ័ពេញមួយសប្តាហ៏ ។ មនុស្សប្រភេទ នោះឯងមិនមែនខ្លាំងខាងវិញ្ញាណទេ ។

គាត់ត្រូវតែធ្វើការសំរេចចិត្តអោយបានច្បាស់លាស់ថាតើ គាត់ត្រូវបំរើព្រះគ្រិស្តមួយរយភាគរយ រឺក៏ រស់នៅសំរាប់តែខ្លួនឯង ។ វាមិនមែនជាការល្អទេ ដែលធ្វើជាគ្រិស្តបរិសទ័តែសំរាប់ថ្ងៃអាទិត្យ ។ មនុស្សម្នាក់ដែលមានវិញ្ញាណខ្លាំងគឺជាមនុស្សម្នាក់ដែលបានសំរេចចិត្តយ៉ាងមុតមាំរស់នៅដើម្បីព្រះគ្រិស្ត ហើយដាក់ព្រះគ្រិស្តមុនគេក្នុងជីវិតរបស់គាត់ ។

## ២. អ្នកធ្វើការសំរេចចិត្ត ក្រោយពីអ្នកមើលឃើញនូវអ្វីដែលព្រះគម្ពីរប្រាប់អ្នកអោយធ្វើ

ជារៀងរាល់ថ្ងៃ យើងទាំងអស់គ្នាប្រឈមមុខទៅនឹងការសំរេចចិត្តនានា ។ តើអ្នកធ្វើការសំរេចចិត្តដោយរបៀបណា? មនុស្សម្នាក់ដែលមានវិញ្ញាណខ្លាំងមិនអនុញ្ញាត្តិអោយអារម្មណ៏របស់គាត់មកគ្រប់គ្រងលើការសំរេចចិត្តរបស់គាត់នោះទេ ។ អ្នកមិនគួរអនុញ្ញាត្តិអោយបំណងប្រាថ្នា រឺក៏ សម្ពាធន៏មិត្តភ័ក្តិមកគ្រប់គ្រងលើការសំរេចចិត្តរបស់អ្នកនោះឡើយ ។

មនុស្សម្នាក់ដែលខ្លាំងខាងវិញ្ញាណគឺ មានការខ្វល់ខ្វាយយ៉ាងខ្លាំងអំពីអ្វីដែលព្រះជាម្ចាស់ចង់អោយគាត់ធ្វើ ។ គាត់មានបំណងចង់សិក្សាព្រះគម្ពីរ ហើយ ស្វែងរកនូវការណែនាំសាមញ្ញនានាដើម្បីប្រើក្នុងការជួយគាត់អោយធ្វើការសំរេចចិត្តបានត្រឹមត្រូវ ។ គាត់មិនចង់ធ្វើជាចៅហ្វាយលើខ្លួនឯងនោះទេ ។ គាត់ចង់អោយព្រះយេស៊ូគ្រិស្តធ្វើជាអ្នកដឹកនាំលើជីវិតរបស់គាត់ ដូច្នេះហើយបានជាគាត់ចង់ស្វែងរកអោយឃើញនូវអ្វីដែលព្រះយេស៊ូចង់អោយគាត់ធ្វើ ។

គាត់មានសុខចិត្តឈរតែឯង ប្រសិនបើចាំបាច់ ។ នៅក្នុងមេរៀន នៃមេរៀនអធិប្បាយរបស់ព្រះយេស៊ូ ទ្រង់បាននិយាយអំពីអស់ណាដែលបានបំណងប្រាថ្នាផ្ទាល់ខ្លួនទៅមុនព្រះជាម្ចាស់ ។ ការឆ្លើយតបរបស់ព្រះយេស៊ូគឺ "ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និង សេចក្តីសុចរិករបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត ។" ម៉ាថាយ ៦:៣៣ ។

មនុស្សម្នាក់ដែលខ្លាំងខាងវិញ្ញាណគឺខ្វល់ខ្វាយអំពីអ្វីដែលព្រះជាម្ចាស់គិតអំពីរាល់ការសំរេចចិត្តរបស់គាត់ ។ នេះមិនមានន័យថា អ្នកត្រូវតែលឺព្រះបន្ទូលដ៏ពិសេសពីព្រះជាម្ចាស់ មុនពេលដែលអ្នកធ្វើការសំរេចចិត្តណាមួយនោះទេ ។ ព្រះគម្ពីរពោរពេញទៅឱវាទជាច្រើនទាក់ទាងទៅនឹងការសំរេចចិត្តនានា ដែលអ្នកប្រឈមមុខជាមួយ ។ ចំនុចគន្លឹះនោះគឺ "តើអ្នកពិតជាចង់អោយព្រះជាម្ចាស់គ្រប់គ្រងលើជីវិតរបស់អ្នកជារៀងរាល់ថ្ងៃដែរឬទេ?" ។

## ៣. ការអធិស្ឋានគឺជាផ្នែកមួយដ៏មានសារៈសំខាន់នៅក្នុងជីវិតរបស់អ្នក

ការអធិស្ឋានគឺជាការនិយាយទៅកាន់ព្រះជាម្ចាស់ និង អនុញ្ញាតិអោយទ្រង់និយាយមកកាន់អ្នកវិញ ។ មនុស្សម្នាក់ដែលខ្លាំងខាងវិញ្ញាណអោយតំលៃយ៉ាងខ្លាំងទៅលើការអធិស្ឋាន ។ ១ថេស្សាឡូនិក ៥:១៧ ចែងថា "មិនដែលឈប់អធិស្ឋានឡើយ" ។ នេះមិនមែនមានន័យថា អ្នកត្រូវចំណាយពេលគ្រប់នាទីនិយាយទៅកាន់ព្រះជាម្ចាស់នោះទេ ។ ប៉ុន្តែពេលពេញមួយថ្ងៃ អ្នកគួរអនុញ្ញាតិអោយចិត្តគំនិតរបស់អ្នក បែរទៅរកព្រះជាម្ចាស់ ហើយនិយាយទៅកាន់ព្រះជាម្ចាស់ -- ដោយការនិយាយលឺៗ ឬក៏ ស្ងាត់ស្ងៀមនៅក្នុងចិត្តគំនិតរបស់អ្នក ។

ព្រះគម្ពីរប្រាប់យើងថា ព្រះជាម្ចាស់ខ្វល់ខ្វាយពីការអធិស្ឋានរបស់យើង ។ "ដ្បិតព្រះជាម្ចាស់ទតមើលមកមនុស្សសុចរិត ហើយទ្រង់ព្រះសណ្តាប់ពាក្យទូលអង្វររបស់គេ ប៉ុន្តែព្រះអង្គជំទាស់នឹងអស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់" ១ ពេត្រុស ៣:១២ ។ ប្រសិនបើអ្នកចង់ខ្លាំងខាងវិញ្ញាណ នោះអ្នកត្រូវអភិវឌ្ឍន៍មិត្តភាពរបស់អ្នកជាមួយនឹងព្រះជាម្ចាស់ ដែលធ្វើឡើងតាមរយៈការអធិស្ឋាន និង ជាផ្នែកមួយដ៏សំខាន់នៅក្នុងជីវិតរបស់អ្នក ។

## ៤. អ្នកកំពុងតែរៀនពីរបៀបស្តាប់សំលេងរបស់ព្រះជាម្ចាស់តាមរយៈវិញ្ញាណរបស់អ្នក

វាជាការងាយស្រួលណាស់សំរាប់យើងទាំងអស់គ្នាភាគច្រើន ដែលនិយាយទៅកាន់ព្រះជាម្ចាស់ ។ ប៉ុន្តែតើវាងាយស្រួលប៉ុណ្ណា ដែលត្រូវស្តាប់សំលេងព្រះជាម្ចាស់? នៅពេលណាដែលអ្នកបានលឺព្រះជាម្ចាស់បានមានបន្ទូលមកកាន់អ្នកចុងក្រោយគេបង្អស់? តើព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់មនុស្សយើងនៅសព្វថ្ងៃដោយរបៀបណា?

ព្រះជាម្ចាស់ជាវិញ្ញាណ ។ ទ្រង់បានបង្កើតយើងម្នាក់ៗមកមានវិញ្ញាណ ។ នៅពេលយើងរស់នៅក្នុងអំពើបាបព្រះគម្ពីរនិយាយថា យើងស្លាប់ខាងវិញ្ញាណ ។ នៅពេលយើងក្លាយជាគ្រិស្តបរិសទ័ ព្រះជាម្ចាស់ដាក់ជីវិតថ្មីនៅក្នុងវិញ្ញាណរបស់អ្នក ។ ហេតុដូចនេះហើយបានជាគ្រិស្តបរិសទ័និយាយអំពីការកើតជាថ្មី ។ វិញ្ញាណរបស់យើងកើតជាថ្មីឡើងវិញ ។ នេះគឺជាផ្នែកមួយនៃជីវិតរបស់អ្នក ដែលព្រះជាម្ចាស់គង់នៅជាមួយ ។

យើងត្រូវរៀនរបៀបស្តាប់ព្រះជាម្ចាស់ នៅពេលដែលទ្រង់មានបន្ទូល ។ វិធីមួយក្នុងចំណោមវិធីដ៏សាមញ្ញផ្សេងទៀត ដែលព្រះជាម្ចាស់និយាយមកកាន់យើងគឺ តាមរយៈព្រះគម្ពីរ -- ព្រះបន្ទូលរបស់ទ្រង់ ។ នៅពេលយើងអានព្រះគម្ពីរ ទ្រង់អាចជួយយើងអោយស្វែងរកឃើញនូវវិធីដ៏ងាយៗពីអ្វីដែលទ្រង់ចង់អោយយើងធ្វើ ។ វាកម្រណាស់ដែលព្រះជាម្ចាស់និយាយមកកាន់យើងនៅក្នុងសំលេងដ៏ខ្លាំង ។ តាមធម្មតា មកតាមរយៈសំលេងហ៊ឹមៗនៅក្នុងវិញ្ញាណរបស់យើង ។ យើងត្រូវតែរៀនស្តាប់ព្រះជាម្ចាស់ ។ នេះគឺចំនុចគន្លឹះមួយដ៏សំខាន់បំផុតក្នុងមានទំនាក់ទំនងដ៏ស៊ីជុំរវាងជាមួយព្រះជាម្ចាស់ ។

## ៥. អ្នកស្រលាញ់ព្រះជាម្ចាស់ជាងមនុស្ស និង របស់ណា១ទៅទៀត

នៅពេលដែលព្រះជាម្ចាស់ទំនាក់ទំនងក្រិតវិន័យរបស់ទ្រង់មកកាន់មនុស្សលោក ទ្រង់បានញែកក្រិតវិន័យពីរទុកជាក្រិតវិន័យដ៏សំខាន់បំផុតជាងក្រិតវិន័យណា១ទៅទៀត ។ ក្រិតវិន័យដ៏សំខាន់បំផុតរបស់ព្រះជាម្ចាស់នោះគឺត្រូវស្រលាញ់ព្រះជាម្ចាស់អោយអស់ពីចិត្ត ពីព្រលឹង ពីគំនិត និង ពីកំលាំងរបស់អ្នក ។ ក្រិតវិន័យដ៏សំខាន់បំផុតទី២គឺត្រូវស្រលាញ់អ្នកជិតខាងរបស់អោយបានដូចស្រលាញ់ខ្លួនឯង ។ (សូមមើល ម៉ាកុស ១២:២៩-៣១) មនុស្សម្នាក់ដែលចង់មានអំណាចខ្លាំងខាងវិញ្ញាណ ត្រូវរៀនស្រលាញ់ព្រះជាម្ចាស់ ។

សេចក្តីស្រលាញ់របស់អ្នកចំពោះព្រះជាម្ចាស់ ត្រូវតែធំជាងសេចក្តីស្រលាញ់របស់អ្នកចំពោះអ្វីណា១ទាំងអស់ ។ អាទិភាពគឺជាចំនុចគន្លឹះនៅទីនេះ ។ តើអ្វីដែលមានសារៈសំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក? ប្រសិនបើព្រះជាម្ចាស់គឺតួអង្គដ៏សំខាន់បំផុត ពេលនោះសេចក្តីស្រលាញ់របស់អ្នកនឹងបង្ហាញប្រាប់ ។ គោលដៅដ៏ចំបងបំផុតនៅក្នុងជីវិតរបស់អ្នកគឺថា ត្រូវស្រលាញ់ព្រះជាម្ចាស់ ។

## ៦. អ្នកបានរៀនពីរបៀបដែលអាចយកឈ្នះលើការល្បួងអោយប្រព្រឹត្តអំពើបាប

មនុស្សម្នាក់ដែលមានអំណាចខាងវិញ្ញាណ បានរៀនតាមរយៈបទពិសោធន៏ពីរបៀបតតាំងនឹងការល្បួងនានា ។ មារសាតាំងវាយប្រហារគ្រប់អ្នកជឿទាំងអស់ ហើយ វានឹងព្យាយាមបំបាក់ទឹកចិត្តរបស់អ្នក អោយអ្នកជឿថា អ្នកគឺជាអ្នកបរាជ័យ ។ ព្រះជាម្ចាស់បានសន្យាថា គង់នៅជាមួយយើង ។ ទ្រង់ក៏បានសន្យាផងដែរថា នឹងប្រទានមធ្យោបាយអោយយើងអាចតទល់នឹងការល្បួងនោះ មកចង់យាយីយើង ។

**១ កូរិនថូស ១០:១៣**

**គ្មានការល្បួងណាមួយកើតមានដក់បងប្អូន ក្រៅពីការល្បួងដែលមនុស្សលោកតែងជួបប្រទះនោះឡើយ ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ទ្រង់មិនបណ្តោយអោយមារល្បួងបងប្អូនហួសពីកំលាំងបងប្អូនទេ ប៉ុន្តែនៅពេលបងប្អូនជួបការល្បួង ព្រះអង្គនឹងប្រទានមធ្យោបាយអោយបងប្អូនចេញរួច និង អោយបងប្អូនអាចទ្រាំទ្របាន ។**

មនុស្សម្នាក់ដែលខ្លាំងខាងវិញ្ញាណចង់យកឈ្នះលើការល្បួងនានា ដែលចង់អោយគាត់ទៅប្រព្រឹត្តអំពើបាប ។ អស់អ្នកដែលខ្សោយខាងវិញ្ញាណ ចង់ចូលរួមនៅក្នុងអំពើបាបនោះដែលនៅពីមុខពួកគេ ។ ពួកគេជ្រើសរើសធ្វើព្រងើយកន្តើយដាក់ជំនួយរបស់ព្រះជាម្ចាស់ ហើយសុខចិត្តទៅចូលរួមប្រព្រឹត្តអំពើបាប ។ ប្រសិនបើអ្នកចង់អោយមាន

អំណាចខ្លាំងខាងវិញ្ញាណ អ្នកត្រូវតែធ្វើតាមឱវាទនៅក្នុងព្រះបន្ទូល ១ ពេត្រុស ៣:១១ គឺថែងថា "ចូរងាកចេញពីអ្វីដែលជាទង្វើបាប តែធ្វើអ្វីដែលជាអំពើល្អវិញ ។ សូមស្វែងរកសន្តិភាព និង សូមទៅដើម្បីសន្តិភាពនោះ ។

**យ៉ាកុប ១:២-៤**

**បងប្អូនអើយ ទុក្ខលំបាកគ្រប់យ៉ាងដែលបងប្អូនត្រូវឆ្លងកាត់នោះ សូមចាត់ទុកជាការដែលធ្វើអោយបងប្អូនមានអំណរដ៏បរិបូណ៌វិញ ដោយដឹងថាការល្បងលមើលជំនឿរបស់បងប្អូននឹងនាំអោយបងប្អូនចេះស៊ូទ្រាំ ។ ក៏ប៉ុន្តែត្រូវអោយការស៊ូទ្រាំទាំងនេះ បង្កើតចេញជាផលផ្លែដ៏ល្អគ្រប់លក្ខណៈដើម្បីអោយបងប្អូនបានគ្រប់លក្ខណៈ មានគុណសម្បត្តិល្អសព្វគ្រប់ ឥតខ្វះត្រង់ណាឡើយ ។**

លទ្ធផលចុងបញ្ចប់នៃការដាក់ខគម្ពីរទាំងនេះជាសកម្មភាពនៅក្នុងជីវិតរបស់អ្នកគឺជាអំណាចខាងវិញ្ញាណ ។ ប៉ុន្តែគ្មានផ្លូវកាត់ណាមួយដែលអាចឈានទៅរកការរីកចំរើននេះបានទេ ។ របៀបដែលយើងឆ្លើយតប កំណត់ពីរបៀបដែលយើងនឹងទទួលបទពិសោធន៍បានភ្លាមៗនូវការរីកចំរើនខាងវិញ្ញាណដ៏ពិតប្រាកដ ។

## ៧. ជីវិតរបស់អ្នក បង្ហាញពីផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ

ប្រសិនបើមនុស្សម្នាក់ពិតជាចង់អោយព្រះជាម្ចាស់ធ្វើជាលេខមួយនៅក្នុងជីវិតរបស់គាត់ នោះគាត់នឹងខិតខំធ្វើកិច្ចការដើម្បីអភិវឌ្ឍន៏ចរិតលក្ខណៈទាំងអស់នោះ ដែលព្រះជាម្ចាស់ចង់អោយមាន ។ នៅពេលដែលអ្នកក្លាយជាគ្រិស្តបរិសទ័ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមក និង គង់នៅក្នុងវិញ្ញាណរបស់អ្នក ។ ប៉ុន្តែអ្នកត្រូវតែជ្រើសរើសអនុញ្ញាតិអោយទ្រង់មានឥទ្ធិពលលើជីវិតរបស់អ្នក និង អាកប្បកិរិយារបស់អ្នក ។

នៅពេលដែលអ្នកចាប់ផ្តើមធ្វើតាមវិធី ដែលទ្រង់ចង់អោយអ្នករស់នៅ ពេលនោះអ្នកនឹងបង្ហាញពីជីវិតដែលមាន "ផលផ្លែខាងវិញ្ញាណ" ដូចដែលមានរៀបរាប់នៅក្នុង កាឡាទី ៥:២២-២៣ ។ "ប៉ុន្តែផលផ្លែនៃព្រះវិញ្ញាណគឺសេចក្តីស្រលាញ់, អំណរ, សន្តិភាព, ចិត្តអត់ហ្មត់, ចិត្តសប្បុរស, ចិត្តល្អ, ភាពស្មោះត្រង់, ចិត្តសុភាពរាបសារ និង ចេះទប់ចិត្តខ្លួនឯង" ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកអភិវឌ្ឍន៏លក្ខណៈទាំងអស់នេះនៅក្នុងជីវិតរបស់អ្នក ប៉ុន្តែអ្នកត្រូវធ្វើការជាមួយទ្រង់ដើម្បីសំរេចចិត្តកិច្ចការទាំងអស់នេះ ។

## ៨. កុំព្យាយាមយកតំរាប់តាមអំណាចរបស់ព្រះជាម្ចាស់

អំណាចខាងវិញ្ញាណដ៏ពិតប្រាកដ ដែលមកពីព្រះជាម្ចាស់គឺមានសំរាប់គ្រប់គ្រិស្តបរិសទ័ទាំងអស់ ។ គ្មាននរណាម្នាក់អាចយកតំរាប់តាមអំណាចរបស់ព្រះជាម្ចាស់បានរយៈពេលយូរអង្វែងទេ ។ អំណាចខាងវិញ្ញាណដ៏ពិតប្រាកដនឹងឈរយ៉ាងរឹងមាំប្រឆាំងនឹងការល្បួងលនានា ដែលមារសាតាំងនាំយកមកប្រឆាំងនឹងគ្រិស្តបរិសទ័ ។ ប៉ុន្តែអស់អ្នកណាដែលព្យាយាមយកតំរាប់តាមអំណាចរបស់ព្រះជាម្ចាស់ នឹងរកឃើញភ្លាម១នូវអំណាចរបស់មារសាតាំងគឺមានពិតប្រាកដ ហើយមានអំណាចខ្លាំងជាងអំណាចក្លែងបន្លំរបស់វាទៀតផង ។ នៅក្នុងគម្ពីរ កិច្ចការជំពូក១៩ ប្រាប់ពីសាច់រឿងពីរបៀបនៃកូនប្រុសទាំង៧នាក់របស់លោកស្កេវ៉ា បានព្យាយាមសំដែងអំណាចនៃការអស្ចារ្យ ដោយគ្មានអំណាចខាងវិញ្ញាណរបស់ព្រះជាម្ចាស់នៅជាមួយពួកគេ ។

**កិច្ចការ ១៩:១៣, ១៥-១៦**

**មានគ្រូដេញវិញ្ញាណអាក្រក់ជាតិយូដាខ្លះ តែងធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយចង់ដេញវិញ្ញាណអាក្រក់ចេញពីមនុស្ស ដោយប្រើព្រះនាមព្រះអម្ចាស់យេស៊ូ គឺគេនិយាយទៅវិញ្ញាណអាក្រក់ថា "យើងបញ្ជាពួកឯងក្នុងព្រះនាមព្រះយេស៊ូដែលលោកប៉ូលប្រកាស ចូរចេញទៅ ។ វិញ្ញាណអាក្រក់តបមកអ្នកនោះវិញថា "យើងស្គាល់ព្រះយេស៊ូ ហើយក៏ដឹងថាលោកប៉ូលជានរណាដែរ ចុះឯងរាល់វិញ ឯងជានរណា?" ។ អ្នកដែលមានអាក្រក់ចូលបានស្ទុះមកសង្កត់ពួកគេជាប់ ហើយវិញ្ញាណអាក្រក់មានកំលាំងជាង រហូតទាល់តែធ្វើអោយអ្នកទាំងនេះរត់ចេញពីផ្ទះរបួតខោត របួតអាវ និងត្រូវរបួសទៀតផង ។**

កុំព្យាយាមធ្វើតំរាប់តាមអំណាចខាងវិញ្ញាណដ៏ពិត ។ ត្រូវធានាថា អ្នកមានរបស់ពិតប្រាកដ ។ យើងត្រូវការអំណាចខាងវិញ្ញាណដ៏ពិតប្រាកដ ដើម្បីប្រយុទ្ធប្រឆាំងនឹងសង្គ្រាមខាងវិញ្ញាណ ដែលយើងជួបប្រឈមមុខនៅក្នុងបទពិសោធន៍ប្រចាំថ្ងៃរបស់យើង ។ យើងត្រូវមានការប្រុងប្រយត្ន័ក្នុងពន្យល់ពីភាពខុសគ្នារវាងសង្គ្រាមខាងវិញ្ញាណ រឺបញ្ហាខាងវិញ្ញាណ ហើយចំនុចមួយផ្សេងទៀតដែលមិនមែនជាការទាក់ទងខាងវិញ្ញាណ ។

អ្នកមិនចាំបាច់ត្រូវការអំណាចខាងវិញ្ញាណ ដើម្បីចងខ្សែស្បែកជើងរបស់អ្នកនោះទេ រឺក៏ លាងមុខរបស់អ្នក ។ ការនោះគ្រាន់តែត្រូវការកំលាំងខាងសាច់ឈាម និង ការបង្ហាត់បង្រៀនដ៏សាមញ្ញស្តីពីរបៀបធ្វើកិច្ចការទាំងនេះ ។ ទោះបើកូនមានអាយុតិចក៏អាចរៀនចេះធ្វើកិច្ចការទាំងអស់នេះបានផងដែរ ។ ប៉ុន្តែអ្នកពិតជាត្រូវការអំណាចខាងវិញ្ញាណដើម្បីតទល់នឹងការល្បួងដែលនាំអ្នកអោយប្រព្រឹត្តអំពើបាប ។ នៅពេលដែលអ្នកធ្វើការជាមួយមនុស្សម្នាក់ដែលតែងតែខាំអ្នកគ្រប់ពេលវេលា នោះត្រូវការអំណាចមកពីព្រះជាម្ចាស់ជាខ្លាំង ដើម្បីបង្ហាញសេចក្តីស្រលាញ់ដល់

មនុស្សនោះ ។ គ្រប់ពេល ដែលអ្នកញៀនស្រាឃើញស្រាបៀមួយកំប៉ុង ដែលធ្វើអោយគាត់ចង់បានកំលាំងដោយការផឹកស្រានោះ ដូច្នេះគាត់ត្រូវការកំលាំងពីព្រះជាម្ចាស់ដើម្បីតទល់នឹងការល្បួងនោះ ។

## ឃ. ចំនុចគន្លឹះនៃពាក្យទាំង៤យ៉ាងចំពោះជីវិតនៃអំណាចខាងវិញ្ញាណ

អំណាចខាងវិញ្ញាណមិនធ្លាក់មកដោយស្វ័យប្រវត្តិលើគ្រិស្តបរិសទ័នោះទេ ។ ព្រះជាម្ចាស់នឹងធ្វើការជាមួយអ្នក ហើយពង្រឹងអ្នក នៅពេលដែលអ្នកបំពេញការទទួលខុសត្រូវរបស់អ្នក ក្នុងនាមបុត្រ និង ជាអ្នកដើរតាមរបស់ព្រះអង្គ ។ ចំនុចគន្លឹះនៃពាក្យទាំង៤យ៉ាងពិតណិនាផ្នែកសំខាន់ៗជាច្រើននៃការអភិវឌ្ឍន៏អំណាចខាងវិញ្ញាណ ។ ពាក្យទាំងបួននោះគឺ -- ជំនឿ, ភាពស្មោះត្រង់, សេចក្តីសង្ឃឹម, និង ទំនុកចិត្ត -- គឺជារឿយៗ ត្រូវបានច្រឡំ និង ត្រូវបានប្រើប្រាស់ខុសនៅក្នុងរង្វង់ជំនឿរបស់គ្រិស្តបរិសទ័ ។ គោលបំណងរបស់យើងនៅត្រង់ចំនុចនេះ គឺមិនមានចង់បញ្ជាក់ពីនិយមន័យយ៉ាងល្អឥតខ្ចោះលើពាក្យនីមួយៗនោះទេ ។ យើងពិតជាចង់កំណត់អោយបានច្បាស់នូវពាក្យគន្លឹះនីមួយៗ ដែលនឹងបង្ហាញពីភាពខុសគ្នារវាងពាក្យនីមួយៗទាំងនោះ ។ យើងក៏នឹងសិក្សាផងដែរទៅពាក្យនីមួយនេះ ដែលវាអាចជួយកសាងជំនឿនៅក្នុងជីវិតរបស់អ្នកជឿ ។

### ១. ជំនឿ

ជំនឿគឺជាការយល់ព្រមជាមួយនឹងព្រឹត្តិការណ៏ពិតៗ ។ អ្នកទទួលយកវាដាក់នៅក្នុងគំនិតរបស់អ្នកថាវាជាការពិត ។ "ខ្ញុំជឿអ្នក នៅពេលដែលអ្នកនិយាយថា ចង្ក្រានដាំបាយក្តៅ" នរណាម្នាក់ក៏ជឿថាវាអញ្ចឹង -- វាគឺជាអ្វីមួយដែលអ្នកធ្វើនៅក្នុងគំនិតរបស់អ្នក ។

### ២. ទំនុកចិត្ត

ទំនុកចិត្តលើសពីពាក្យថា ជំនឿទៅទៀត គឺថា មានទំនុកចិត្តនៅក្នុងមនុស្សម្នាក់ផ្សេងទៀត ។ អ្នកពឹងផ្អែកលើមនុស្សម្នាក់នោះដោយវិធីណាមួយ ។ លោកកែវនិយាយថា "ខ្ញុំនឹងយកលុយមកនៅយប់នេះ" ។ អ្នកអាចជ្រើសរើសជឿលើអ្វីដែលគាត់និយាយ ប៉ុន្តែពេលនោះអ្នកត្រូវធ្វើការសំរេចចិត្ត តើអ្នកនឹងទុកចិត្តនូវអ្វីដែលគាត់និយាយ រឺក៏តើអ្នកនឹងជ្រើសរើសមិនទុកចិត្តលើអ្វីដែលគាត់និយាយ? ទំនុកចិត្តជាធម្មតាត្រូវបានកសាងឡើងរវាងមនុស្សពីរនាក់នៅពេលដែលពេលវេលាចេះតែរំកិល ។ ភាពស្មោះត្រង់ និង ការដែលអាចពឹងពាក់របស់ពួកគេកាន់តែច្រើនយ៉ាងណានោះក៏មានការទុកចិត្តទៅលើពួកគេក៏ច្រើនយ៉ាងនោះដែរ ។

អ្នកក៏អាចអភិវឌ្ឍន៍ទំនុកចិត្តដើម្បីកិច្ចការផ្សេងៗទៀតផងដែរ ។ ខ្ញុំទុកចិត្តលើកៅអីនេះ ។ គ្រប់ពេលដែលខ្ញុំអង្គុយលើ វាទប់នូវទំងន់ខ្ញុំជាប់មិនអោយបាក់ឡើយ ។ តាមបទពិសោធន៏ចាស់ដែលអង្គុយលើកៅអីមិនអី ពេលនោះតាមធម្មតាយើងនឹងដើរចូលកាន់ការិយាល័យ ហើយអង្គុយលើកៅអីដោយមានទំនុកចិត្តថា កៅអីនេះមិនបាកឡើយ ។ យ៉ាងណាក៏ដោយ ប្រសិនបើកៅអីអង្គុយនេះសភាពកោង រឺជើងមួយរបស់វាបត់ យើងប្រហែលជាមិនជាប្រញាប់ក្នុងការអង្គុយលើកៅអីនោះទេ ។ រឺប្រសិនបើអ្នកទើបតែជួបក្នុងអង្គុយលើកៅអីហើយបាក់ នោះប្រហែលជាអ្នកត្រូវត្រួតពិនិត្យយ៉ាងប្រុងប្រយត្ន័លើកៅអីផ្សេងទៀតមុននឹងអ្នកអង្គុយលើវា ។

ការទុកចិត្តគឺជាការសំរេចចិត្តខាងមនសិកា ។ ប៉ុន្តែទំនុកចិត្តមានលក្ខណៈស៊ីជុំរៅជាង -- វាគឺជាការសំរេចចិត្តដែលកើតចេញពីចិត្ត ។ គ្រប់ពេលដែលយើងទុកចិត្តលើអ្វីមួយ យើងសំរេចចិត្តធ្វើកិច្ចការនោះ ។ មានមនុស្សមួយចំនួនមានពេលវេលាដ៏លំបាកក្នុងការទុកចិត្តលើមនុស្សផ្សេងទៀត ដោយព្រោះពួកគេធ្លាប់បានធ្វើអោយឈឺចាប់កាលពីអតីតកាល ដែលពួកគេធ្លាក់ទុកចិត្តពីមុនមក ។ ប្រហែលជា អ្នកធ្លាប់មានមិត្តភ័ក្តិម្នាក់ ដែលបានធ្វើអោយអ្នកខចិត្តដោយការនិយាយកុហក រឺក៏ លួចរបស់ទ្រព្យរបស់អ្នក ។ រឺក៏ប្រហែលជាពួកគេបរាជ័យដោយមិនបានធ្វើតាមពាក្យសន្យាដែលពួកគេធ្លាប់បានសន្យាជាមួយអ្នក ។ ទំនុកចិត្តរបស់នៅលើមនុស្សម្នាក់នោះគឺត្រូវបានបំផ្លាញហើយ ។

មានមនុស្សមួយចំនួនមានពេលវេលាដ៏លំបាកនៅក្នុងការរៀនទុកចិត្តលើព្រះជាម្ចាស់ ។ "ខ្ញុំមិនអាចមើលឃើញព្រះជាម្ចាស់ទេ ។ ទ្រង់មិនដែលនិយាយមកកាន់ខ្ញុំនៅក្នុងសំលេងមួយដែលខ្ញុំអាចស្តាប់លឺបាននោះទេ ។ តើខ្ញុំដឹងថាទ្រង់ពិតជាព្រះមែនដោយរបៀបណា? តើអោយខ្ញុំអាចទុកចិត្តលើព្រះជាម្ចាស់ដោយរបៀបណា?" ការទុកចិត្តគឺជាជំរើស ។ អ្នកពិតជាប្រថុយប្រថាន នៅពេលអ្នកទុកចិត្តលើនរណាម្នាក់ ។ អ្នកក៏ត្រូវធ្វើកិច្ចការនេះជាមួយព្រះជាម្ចាស់ផងដែរ ។ ប៉ុន្តែកុំព្រួយបារម្ភអ្វីឡើយ ព្រះជាម្ចាស់មានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់ ។ អ្នកអាចដាក់ទំនុកចិត្តទាំងស្រុងរបស់អ្នកនៅលើទ្រង់បាន ។ ទ្រង់នឹងមិនបោះបង់ចោលអ្នកឡើយ ។ នៅពេលដែលអ្នកមើលឃើញព្រះជាម្ចាស់ធ្វើការនៅក្នុងជីវិតរបស់អ្នក ហើយ ជួយអ្នកអោយយកឈ្នះលើការល្បួងនានា និង បញ្ហាផ្សេងៗ នោះអ្នកនឹងមានមូលហេតុជាច្រើនថែមទៀតដើម្បីទុកចិត្តលើព្រះជាម្ចាស់ ។

## ៣. សេចក្តីសង្ឃឹម

ខណៈដែលពាក្យថា ទុកចិត្ត និយាយស្តីពីតែបទពិសោធន៏កាលពីអតីតកាល តែឯពាក្យថា សេចក្តីសង្ឃឹមនិយាយសំដៅទៅពេលអនាគតវិញ ។ សង្ឃឹមគឺជាការរំពឹងទុកនូវអ្វីមួយដែលត្រូវកើតឡើងក្នុងពេលអនាគត ។ ពាក្យសេចក្តីសង្ឃឹម និង ពាក្យទុកចិត្តមានទំនាក់ទំនងនិងគ្នាយ៉ាងជិតស្និត ។ ប៉ុន្តែពាក្យថា សេចក្តីសង្ឃឹមគឺសំដៅទៅតែ

នាពេលអនាគតប៉ុណ្ណោះ ។ អ្នកមិនសង្ឃឹមថា ត្រូវបរិភោគអាហារកាលពីម្សិលមិញទេ ។ អ្នកគួរតែអាចចងចាំនូវអ្វី ដែលបានកើតឡើង ហើយ និយាយថា "ខ្ញុំដឹងថា ខ្ញុំបានញ៉ាំអាហារពេលល្ងាច" មានតែពាក្យថាជំនឿទេ ដែលតំរូវ អោយនិយាយឃ្លានោះ ។ ប៉ុន្តែចុះយប់នេះវិញ រឺក៏ ព្រឹកថ្ងៃស្អែកវិញ? តើអ្នកនឹងអាចញ៉ាំបានទេ? ពាក្យថាសេចក្តី សង្ឃឹមគឺត្រូវការឥឡូវនេះ ។ ប្រសិនបើអ្នកគ្មានលុយ រឺក៏ ម្ហូបអាហារទេ ពេលនោះអ្នកអាចមានសំនួរពិតប្រាកដមួយ ចំនួននៅក្នុងគំនិតរបស់អ្នកស្តីពីអាហាររបស់អ្នកនៅពេលបន្ទាប់ ។ ប៉ុន្តែប្រសិនបើអ្នកមានអាហារជាច្រើននៅឯផ្ទះ ហើយលុយជាច្រើននៅក្នុងហោប៉ៅរបស់អ្នក វាមិនចាំបាច់តំរូវអោយអ្នកមានសេចក្តីសង្ឃឹមច្រើន នៅពេលដែលអ្នក ទន្ទឹងរងចាំអាហារបន្ទាប់របស់អ្នកនោះទេ ។

ឥឡូវនិយាយថា អ្នកខ្ចី១០ដុល្លាពីមិត្តភ័ក្តិម្នាក់ ហើយគាត់បាននិយាយថា គាត់នឹងសងអ្នកវិញនៅយប់នេះ ។ នៅក្នុងស្ថានភាពនេះ សេចក្តីសង្ឃឹមនឹងមានចំនុចសំខាន់ៗជាច្រើន ជាពិសេស ប្រសិនបើអ្នកពិតជាត្រូវការលុយនោះ មកវិញនៅវេលាម៉ោង ៨ព្រឹកថ្ងៃស្អែក ។

សេចក្តីសង្ឃឹមគឺជាបញ្ហាដ៏ចំបងនៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ ។ ព្រះយេស៊ូបានមានបន្ទូល មុនពេលដែលទ្រង់ បានយាងចាកចេញពីផែនដីនេះថា ទ្រង់នឹងយាងត្រឡប់មកវិញដើម្បីយើង ហើយនឹងយកយើងទៅស្ថានបរមសុខ ។ ប្រសិនបើយើងស្លាប់មុនពេលទ្រង់យាងមក ទ្រង់ក៏បានសន្យាប្រទានជីវិតអោយយើងក្រោយពីស្លាប់ទៅ ។ យើងដាក់ សេចក្តីសង្ឃឹមរបស់យើងនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូគ្រិស្ត ។ មានមនុស្សរាប់ពាន់នាក់បានទទួលរងទុក្ខវេទនា យ៉ាងខ្លាំង ដោយព្រោះតែមានជំនឿលើព្រះជាម្ចាស់ ។ មនុស្សទាំងអស់នេះមានសេចក្តីសង្ឃឹមថា ជីវិតក្រោយពីស្លាប់ ទៅនឹងប្រសើរជាងជីវិតដ៏ប្រសើរនៅលើផែនដីនេះទៅទៀត ។ សូមមើល ហេប្រឺ ១១ ។

## ៤. ជំនឿ

ប្រសិនបើអ្នកមើលលើពាក្យថា "ជំនឿ" នៅក្នុងវចនានុក្រមធំមួយ នោះអ្នកនឹងប្រហែលជាឃើញនូវនិយម ន័យជាច្រើនចេញមក ។ វាក៏បង្ហាញផងដែរនូវពាក្យថា ជំនឿ សេចក្តីសង្ឃឹម និង ការទុកចិត្ត ។ តើពាក្យទាំងអស់នេះ មានន័យដូចគ្នាទាំងអស់ដែរឬទេ? ពាក្យទាំងបួននេះមានទំនាក់ទំនងជាមួយនឹងគ្នាយ៉ាងជិតស្និត ។ យ៉ាងណាក៏ដោយ ពាក្យថា ជំនឿនៅសព្វថ្ងៃនេះត្រូវបានគេប្រើ ដែលមានអត្ថន័យដូចទៅនឹងពាក្យទាំងនេះផងដែរ ។

នៅពេលដែលអ្នកនិយាយថា "ខ្ញុំមានជំនឿនៅលើកៅអីនេះ ។ ខ្ញុំមិនច្បាស់ថាតើ វាអាចទប់ខ្ញុំជាប់ នៅពេល ដែលខ្ញុំអង្គុយរឺយ៉ាងណានោះទេ" ជំនឿមានន័យដូចជាពាក្យថា ទុកចិត្ត ។ នៅពេលដែលកុមារម្នាក់មក ហើយ ប្រាប់

ម្ដាយរបស់គាត់ "ខ្ញុំបានសំអាតបន្ទប់របស់ខ្ញុំរួចរាល់ហើយ" ម្ដាយអាចឆ្លើយទៅវិញថា "ម៉ាក់មានជំនឿនៅលើពាក្យសំដីរបស់កូនហើយ" ម្ដាយនោះគួរតែបានប្រើពាក្យ ជឿ រឺក៏ ទុកចិត្ត ហើយប្រាប់សារនេះយ៉ាងសាមញ្ញដល់កូនរបស់គាត់ ។

យ៉ាងណាក៏ដោយ នៅក្នុងមេរៀននេះ យើងចង់ព្យាយាមចាប់យកនូវគោលគំនិតដ៏ប្រសើរ ពីអ្វីដែលព្រះគម្ពីរមានន័យ នៅពេលដែលព្រះគម្ពីរប្រើពាក្យថា ជំនឿ ។ ព្រះយេស៊ូបានមានបន្ទូលថា "ខ្ញុំសូមប្រាប់អោយអ្នករាល់គ្នាដឹងជាប្រាកដថា ប្រសិនបើអ្នកមានជំនឿដូចជាគ្រាប់ល្ហិតតូចមួយ នោះអ្នកអាចនិយាយទៅកាន់ភ្នំនេះថា ចូររំកិលពីទីនេះទៅកាន់ទីនោះទៅ ហើយវានឹងធ្វើតាមជាមិនខាន ។ គ្មានអ្វីណាមួយដែលពិបាកសំរាប់អ្នកឡើយ ។ ម៉ាថាយ ១៧:២០ វាហាក់បីដូចជាច្បាស់ណាស់ ដែលព្រះយេស៊ូប្រើពាក្យនៅទីនេះថា ជំនឿ ដែលមានន័យលើសពីពាក្យថាជឿនៅក្នុងគំនិតរបស់អ្នកដែលថា អ្នកអាចធ្វើរឿងទាំងនោះបាន ។ ប្រសិនបើពាក្យថា ជំនឿមានន័យដូចជាពាក្យជឿនៅក្នុងខគម្ពីរនេះ ហើយប្រសិនបើខនោះត្រឹមត្រូវ ពេលនោះនរណាម្នាក់ក៏អាចរៀបចំភ្នំនោះបានសារជាថ្មី រឺក៏ ដាក់ជាទួលដូចជាភ្នំជាដើម ។ ហើយយើងមិនចាំបាច់ត្រូវរឡូលិនដី ដើម្បីជួយធ្វើកិច្ចការនេះឡើយ ។

ពាក្យថា "ជំនឿ" ត្រូវបានប្រើច្រើនជាងគេនៅក្នុងព្រះគម្ពីរ ។ ជួនកាលវាលេចមកមានន័យស្រដៀងទៅនឹងពាក្យថា ជឿ ។ នៅក្នុងខគម្ពីរផ្សេងទៀត វាមានន័យថា ភាពស្មោះត្រង់ រឺក៏ ដែលអាចទុកចិត្តបាន រឺក៏ ដែលអាចពឹងពាក់បាន ។ យ៉ាងណាក៏ដោយ សេចក្ដីបង្រៀន និង ពន្ធកិច្ចរបស់ព្រះយេស៊ូ ហាក់បីដូចជានាំយកមកនូវចរិតលក្ខណៈដ៏ពិសេសមួយនៃពាក្យថា ជំនឿ ។ និយមន័យខាងក្រោមស្ដីពីជំនឿ មិនព្យាយាមរួមបញ្ចូលគ្រប់ទាំងផ្នែកនៃជំនឿទាំងអស់នោះទេ -- មានតែចំនុចផ្សេងគ្នាមួយប៉ុណ្ណោះ ដែលញែកដាច់ចេញពីពាក្យថា ជំនឿ, សេចក្ដីសង្ឃឹម និង ការទុកចិត្ត ។

**ជំនឿគឺជាអំណាចមកពីព្រះជាម្ចាស់ ដែលតែងតែនាំអោយកើតជាសកម្មភាព ។** ជំនឿគឺជាផ្នែកគន្លឹះមួយនៃអំណាចខាងវិញ្ញាណ ។ នៅពេលដែលព្រះយេស៊ូបានមានបន្ទូលអំពីការប្រើជំនឿរំកិលភ្នំចេញ ទ្រង់ទើបតែបានបញ្ចប់ការព្យាបាលក្មេងប្រុសម្នាក់ដែលមានខ្មោចចូល ។ ពួកគេសាវ័កបានបរាជ័យក្នុងដេញខ្មោចនេះអោយចេញ មុនពេលដែលព្រះយេស៊ូបានយាងមកដល់ ។ នៅពេលដែលពួកគេសួរសំនួរថា ហេតុអ្វីបានជាពួកគេមិនអាចធ្វើកិច្ចការនេះបាន ព្រះយេស៊ូក៏បានឆ្លើយថា "ដោយព្រោះអ្នករាល់គ្នាមានជំនឿតិចពេក ។" (ម៉ាថាយ ១៧:២០)

សូមអោយយើងអនុវត្តទៅនឹងនិយមន័យនេះនូវអ្វីដែលបានកើតឡើងនៅក្នុងម៉ាថាយ ១៧:១៤-២១ ។ ដើម្បីព្យាបាលមនុស្សម្នាក់ដែលមានខ្មោចចូល ត្រូវការចំណាយកំលាំងខាងប្រាជ្ញាជាច្រើន -- វាត្រូវការអំណាចដ៏អស្ចារ្យមកពីព្រះជាម្ចាស់ ។ ព្រះយេស៊ូបានអធិស្ឋានសំរាប់ក្មេងប្រុសដែលឈឺ ហើយ រំពេចនោះស្រាប់តែក្មេងនោះបានជាសះស្បើយ ។ ព្រះយេស៊ូមានអំណាចមកពីព្រះជាម្ចាស់ ដែលនាំមកនូវសកម្មភាព ។ ក្មេងប្រុសនោះក៏បានជាសះស្បើយភ្លាមៗនោះផងដែរ ។ ជាដំបូង ពួកសាវក័បានអធិស្ឋានអោយក្មេងប្រុសនោះ ប៉ុន្តែក្មេងនោះពុំបានទទួលការព្យាបាលទេ ។ ជំនឿមកពីព្រះជាម្ចាស់មិនទាន់កើតមាននៅក្នុងជីវិតរបស់ពួកសាវ៉កនៅឡើយទេ ។ តើពួកសាវ៉កបានជឿថា ពួកគេអាចនាំការព្យាបាល មុនពេលពួកគេបានអធិស្ឋានសំរាប់ក្មេងប្រុសឬទេ? អត្ថបទខគម្ពីរមិនបាននិយាយថា ប៉ុន្តែវាហាក់បីដូចជា ដែលថាពួកគេបានមានអារម្មណ៏ថា ពួកគេអាចនោះឡើយ ដោយព្រោះពួកគេបានអធិស្ឋានសំរាប់ក្មេងប្រុសម្នាក់នោះ ។

នៅពេលយើងមើលទៅគ្រប់ទាំងគម្ពីរដំណឹងល្អទាំងអស់ យើងឃើញថា ព្រះយេស៊ូនិយាយពីជំនឿនៅក្នុងទំហំមួយដែល មានទៅដោយការព្យាបាលដ៏អស្ចារ្យ រឺក៏ ការអស្ចារ្យផ្សេងៗទៀត ។ គម្ពីរ អេភេសូ ២:៨-៩ បញ្ជាក់ថា "ដ្បិតអីដោយសារព្រះគុណរបស់ព្រះជាម្ចាស់ ដែលអ្នករាល់គ្នាបានទទួលការសង្គ្រោះតាមរយៈជំនឿ ។ មិនមែនដោយសារកិច្ចខិតខំប្រឹងប្រែងរបស់អ្នកទេ ប៉ុន្តែជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដូច្នេះដើម្បីកុំអោយនរណាម្នាក់អួតខ្លួនបានឡើយ ។ អ្នកត្រូវតែទទួលយក និង ជឿថា ព្រះជាម្ចាស់អាចធ្វើកិច្ចការនេះបានសំរាប់អ្នក ។ ប៉ុន្តែខគម្ពីរទាំងនេះចង្អុលបង្ហាញផងដែរថាជំនឿ -- អំណាចរបស់ព្រះជាម្ចាស់ដែលអាចជំរះអំពើបាបរបស់អ្នកបាន មិនមែនដោយអំណាចពីប្រាជ្ញារបស់អ្នកនោះទេ ។ ការសង្គ្រោះគឺជាការអស្ចារ្យដូចគ្នាទៅនឹងការប្រោសអោយជាដ៏ទៃទៀតផងដែរ ។

ជំនឿគឺជាចំនុចដ៏ជាគន្លឹះមួយនៃការចាក់បង្ហូរអំណាចរបស់ព្រះជាម្ចាស់មកក្នុងជីវិតរបស់យើង ។ ជំនឿមានន័យស៊ីជំរៅជាងការជឿទៅទៀត ។ មានស្ត្រីម្នាក់ដែលមានបញ្ហាធ្លាក់ឈាម បានព្យាយាមរកការព្យាបាលពីវិជ្ជបណ្ឌិតអស់រយៈពេល១២ឆ្នាំមកហើយ ប៉ុន្តែនៅចុងបញ្ចប់នាងបានមកកាន់ព្រះយេស៊ូ បានប៉ះអាវព្រះយេស៊ូ ហើយរំពេចនោះនាងក៏បានជាពីជំងឺ ។ ព្រះយេស៊ូបានឈប់ ហើយបានសួរថា តើមាននរណាបានប៉ះខ្ញុំ?

**លូកា ៨:៤៦-៤៨**

**ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលថា មានម្នាក់ពិតជាបានពាល់ខ្ញុំ ព្រោះខ្ញុំបានដឹងថាមានឫទ្ធានុភាពមួយចេញពីខ្លួនខ្ញុំទៅ ។ ស្ត្រីនោះមកក្រាបទៀបព្រះបាទាព្រះយេស៊ូ ទាំងញ័រទន្ទត់ព្រោះដឹងថាខ្លួនលាក់រឿងនេះមិនជិត ។ នាងទូលព្រះអង្គនៅចំពោះមុខប្រជាជនទាំងមូល អំពីហេតុដែលនាំអោយ**

**នាងពាល់ព្រះអង្គ ហើយនាងបានជាពីជំងឺភ្លាម ។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា កូនស្រីអើយ ជំនឿរបស់នាងបានសង្គ្រោះនាងហើយ សូមអញ្ជើញទៅដោយសុខសាន្តចុះ ។**

ព្រះយេស៊ូបានមានបន្ទូលថា ជំនឿរបស់នាងបានព្យាបាលនាងហើយ ។ វាបញ្ជាក់យ៉ាងច្បាស់ណាស់ពីអ្វីដែលព្រះយេស៊ូបានមានបន្ទូលថា មានអំណាចមួយចេញពីទ្រង់ដើម្បីព្យាបាលជំងឺនោះទាំងស្រុងអោយបានជាសះស្បើយ ។ នាងបានមកកាន់ព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលប្រភពនៃគ្រប់ទាំងអំណាច និង ជំនឿទាំងអស់ ។ នៅក្នុងករណីនេះ ជំនឿបានកើតចេញជាសកម្មភាព -- នាងក៏បានទទួលការព្យាបាលភ្លាមៗនោះ ។

ជំនឿដែលកើតចេញពីព្រះជាម្ចាស់គឺជាជំនឿដ៏ពិសេសមួយប្រភេទ ។ អំណាចនេះមកពីព្រះជាម្ចាស់ជួយយើងនៅក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង ។ ជំនឿនេះជួយយើងអោយប្រយុទ្ធប្រឆាំងទល់នឹងសង្គ្រាមខាងវិញ្ញាណ ។ វាមិនមែនជាអំណាចខាងប្រាជ្ញានោះទេ ។ វាគឺជាអំណាចខាងវិញ្ញាណ ។ ប្រហែលជាយើងនិយាយវាដោយសាមញ្ញថា ជំនឿគឺជាអ្វីៗទាំងអស់ ដើម្បីជួយអ្នកអោយមានអំណាចខាងវិញ្ញាណ ។ សំរាប់កិច្ចការផ្សេងៗទៀតក្រៅពីជំនឿ ដែលមាននៅក្នុងជីវិតរបស់មនុស្សម្នាក់ ដែលមានអំណាចខាងវិញ្ញាណ ។




មានវិធីមួយដើម្បីមើលរូបភាពទាំងបួននេះ គឺជាការគិតអំពីរង្វង់ដែលត្រួតស៊ីគ្នា ។ ពាក្យនីមួយៗមានលក្ខណៈពិសេស ហើយមានភាពផ្សេងៗគ្នា ។ ប៉ុន្តែមានពាក្យមួយទៀតត្រួតស៊ីគ្នាទៅនឹងពាក្យមួយផ្សេងទៀតដែរ ។

យ៉ាងណាក៏ដោយ  ដើម្បីជាប្រយោជន៍នៃការពិភាក្សារបស់យើងនៅក្នុងរៀននេះ  យើងនឹងព្យាយាមប្រើពាក្យនីមួយៗ នៅក្នុងនិយមន័យដ៏ពិសេសរបស់វា ។ ដើម្បីជួយយើងអោយមានភាពងាយស្រួលក្នុងការពិភាក្សា យើងនឹងចាត់ទុកថា រង្វង់នីមួយនឹងមិនត្រួតស៊ីគ្នានោះទេ ហើយពាក្យនីមួយៗមានលក្ខណៈពិសេសរបស់វា ។




អំណាចខាងវិញ្ញាណមានទៅដោយសារធាតុទាំងបួននេះ  ហើយច្រើនថែមទៀតផង  ។  ឥឡូវនេះ  សូមយើង ចំណាយពេលមើលពីចំនុច  ដែលយើងត្រូវប្រើអំណាចខាងវិញ្ញាណនៅក្នុងជីវិតរបស់យើង  ។  ទាំងនេះគឺជាឧទាហរណ៍ មួយចំនួនពីអ្វីដែលអ្នកអាចប្រើជំនឿសំរាប់រឿងរ៉ាវនៅក្នុងជីវិតរបស់អ្នក ។

១.  ការព្យាបាល
២.  ការក្លាយជាគ្រិស្តបរិសទ័ (ការសង្គ្រោះ) អេភេសូ ២:៨-៩
៣.  ធ្វើតាមព្រះទ័យរបស់ព្រះជាម្ចាស់
៤.  បន្តធ្វើជាគ្រិស្តបរិសទ័
៥.  មានអំណាចលើអំពើបាប ១ យ៉ូហាន ៥:៤-៥
៦.  ឆ្លងកាត់ការសាកល្បង និង បញ្ហានានា
៧.  យកឈ្នះលើការល្បួងនានា
៨.  ស្តាប់បង្គាប់ក្រិត្យវិន័យរបស់ព្រះជាម្ចាស់
៩.  សំរាប់តំរូវការបច្ចុប្បន្ន ។ អ្នកមិនអាចរក្សាទុកជំនឿសំរាប់តំរូវការនាពេលអនាគតបានទេ ។

មានគ្រោះថ្នាក់ណាស់សំរាប់គ្រិស្តបរិសទ័ថ្មីៗ   ដែលជាប់ពាក់ពន្ធ័ទៅនឹងការព្យាយាមស្វែងរកនូវនិយមន័យដ៏ ល្អឥតខ្ចោះសំរាប់អំណាចខាងវិញ្ញាណដែលថា  ពួកគេបាត់បង់នូវគោលបំណងរួមរបស់វា  ។  ប្រសិនបើអ្នកនៅតែមាន សំនួរជាច្រើនដែលទាក់ទងទៅនឹងជំនឿ ការជឿ សេចក្តីសង្ឃឹម ការទុកចិត្ត និង អំណាចខាងវិញ្ញាណដ៏ពិត កុំអនុញ្ញាត្តិ អោយការនោះធ្វើអោយអ្នករាំងស្ទះឡើយ  ។ ទុកអោយការនោះដល់ពួកអ្នកព្រះគម្ពីរវិទូ និង  អ្នកទេវសាស្រ្តវិទ្យាគេ

ខ្វាល់ខ្វាយទៅ ។ មកដក់ចំនុចនេះនៅក្នុងជីវិតរបស់អ្នក ចំនុចដ៏សំខាន់នោះគឺ ចាប់ផ្តើមរីកចំរើនខាងវិញ្ញាណ និង ប្រើអំណាចរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នក ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងសង្គ្រាមខាងវិញ្ញាណ ដែលវាហៀបនឹងមកដល់នោះវិញ ។

ប្រសិនបើមានទារកថ្មីម្នាក់បានកើតមកក្នុងគ្រួសាររបស់អ្នក អ្នកមិនចំណាយពេលនៅសប្តាហ៍ដំបូងដើម្បីព្យាយាមអោយទារកនោះស្គាល់ឈ្មោះរបស់វា ស្គាល់អាស្រ័យដ្ឋានរបស់វា ហើយ របៀបដែលវាអាចលើកដុំដែកអោយឡើងសាច់ដុំនោះទេ ។ អ្នកអោយចំណីពិសេស១ដល់វា ដើម្បីជួយវាអោយរីកចំរើនឡើង ហើយត្រូវធានាថា វាត្រូវបានការពារយ៉ាងប្រុងប្រយត្ន័ពីការគ្រោះថ្នាក់ផ្សេង១ដែលអាចកើតមានឡើង ។ នៅក្នុងរបៀបមួយដូចគ្នាផងដែរ ក្នុងការក្លាយជាគ្រិស្តបរិសទ័ ។ អ្នកអាចមានជំងឺខាងវិញ្ញាណ ប្រសិនបើអ្នកចំណាយពេលរបស់អ្នកទាំងអស់ ព្យាយាមឆ្លើយទៅនឹងព័តិមានលំអិតដែលទាក់ទងទៅនឹងជីវិតខាងវិញ្ញាណរបស់អ្នក ប៉ុន្តែនៅពេលជាមួយគ្នានេះ បរាជ័យក្នុងការអនុវត្តន៏ក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកនូវអ្វីដែលអ្នកបានដឹងរួចមកហើយ ។

គោលគំនិតដ៏ចំបងនៃមេរៀននេះគឺធានាថា អ្នកដឹងថា អំណាចខាងវិញ្ញាណរបស់អ្នកមកពីណា ហើយរបៀបដែលអ្នកអាចប្រើអំណាចនេះនៅក្នុងជីវិតរបស់អ្នក ។ អ្នកអនុវត្តសេចក្តីបង្រៀននេះនៅក្នុងជីវិតរបស់អ្នកកាន់តែច្រើននោះអ្នកនឹងងាយយល់កាន់តែច្រើនយ៉ាងនោះដែរ ។

# ជំពូកទី៣
# របៀបទទួលបានអំណាចខាងវិញ្ញាណ

## ក. កុំព្យាយាមស្វែងរកអោយបានធ្វើជារាខាងវិញ្ញាណ

មានពេលជាច្រើនគ្រិស្តបរិសទ័ថ្មីៗ មានការស្រមោលស្រមៃពីការរំភើបដែលថា ប្រសិនបើពួកគេអាចនិយាយទៅកាន់អ្នកជំងឺ ហើយឃើញថា ពួកគេទទួលការព្យាបាលភ្លាមៗ ។ ពួកគេស្រលាញ់ចង់អោយព្រះជាម្ចាស់ប្រើពួកគេធ្វើការអស្ចារ្យដូចដែលព្រះយេស៊ូបានធ្វើផងដែរ ។ ការនេះកម្រកើតឡើងណាស់ ។

មានមេរៀនមួយដ៏សំខាន់ ដែលយើងទាំងអស់គ្នាត្រូវតែរៀនថា យើងមិនប្រាប់ព្រះជាម្ចាស់ថា នៅពេលណាដែលត្រូវសំដែងការអស្ចារ្យនោះទេ ។ យើងទាំងអស់គ្នាមិនមែនជាចៅហ្វាយរបស់ព្រះជាម្ចាស់ ។ គាត់គឺជាអ្នកដឹកនាំលើជីវិតរបស់យើង ។ ព្រះជាម្ចាស់បានបង្កើតយើងទាំងអស់គ្នាសំរាប់ការសប្បាយរីករាយរបស់ទ្រង់ ។ មានមនុស្សមួយចំនួនគិតថា ព្រះជាម្ចាស់គឺជាក្មេងរត់ការរបស់ពួកគេ ដែលអាចបញ្ជាបានគ្រប់យ៉ាងសំរាប់សេចក្តីប៉ងប្រាថ្នារបស់ពួកគេ ។

គម្ពីរដានីយ៉ែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ផ្តល់អោយយើងនូវឧទាហរណ៍មួយដ៏ល្អ ពីការរំពឹងគិតដ៏ត្រឹមត្រូវដែលយើងគួរតែមានស្តីពីព្រឹត្តិការណ៍ដ៏អស្ចារ្យ ។ លោកសាដ្រាក់ មេសាក់ និង អបេឌ៊ិកោបានប្រឈមមុខទៅនឹងសេចក្តីស្លាប់ភ្លាមៗ ។ ពួកគេហៀបនឹងត្រូវបានគេបោះចូលទៅក្នុងឡភ្លើង ។ ស្តេចបានប្រទានឱកាសមួយដល់ពួកគេអោយផ្លាស់ប្តូរគំនិតរបស់ពួកគេ ហើយពួកគេត្រូវអានក្បាល និង ថ្វាយបង្គំរូបសំណាករបស់ស្តេច ។ ការឆ្លើយតបរបស់ពួកគេបង្ហាញពីការទុកចិត្តរបស់ពួកគេលើសមត្ថភាពរបស់ព្រះជាម្ចាស់ ដើម្បីរំដោះពួកគេ ប៉ុន្តែគ្មានជំរុយណាមួយពីពួកគេ ដែលដាក់សំពាធលើព្រះជាម្ចាស់ ដើម្បីជួយពួកគេអោយរួចផុតពីស្ថានភាពដ៏អាក្រក់នេះ ។

**ដានីយ៉ែល ៣:១៦-១៨**

**លោកសាដ្រាក់ មែសាក់ និង អបេឌនេកោ ទូលព្រះចៅនេប៊ូក្នេសាវិញថា ទូលបង្គំយើងខ្ញុំមិនបាច់ឆ្លើយនឹងព្រះករុណាអំពីរឿងនេះទេ ។ បពិព្រះរាជា ព្រះដែលទូលបង្គំយើងខ្ញុំគោរពបំរើពិតជាអាច**

**រំដោះទូលបង្គំយើងខ្ញុំ គឺព្រះអង្គនឹងរំដោះយើងខ្ញុំអោយរួចពីភ្លើងដ៏សន្ធោសន្ធៅ និងអោយយើងខ្ញុំរួចពីព្រះហស្តរបស់ព្រះករុណាជាមិនខាន ។ ទោះបីព្រះអង្គមិនរំដោះយើងខ្ញុំក្តី សូមព្រះករុណាជ្រាបអោយបានច្បាស់ថា ទូលបង្គំយើងខ្ញុំមិនព្រមគោរពបំរើព្រះទាំងប៉ុន្មានរបស់ព្រះករុណាឡើយ ហើយយើងខ្ញុំក៏មិនក្រាបថ្វាយបង្គំរូបបដិមាករមាស ដែលព្រះករុណាបានកសាងនេះដែរ ។**

ប្រសិនបើអ្នកបានអានពីសាច់រឿងក្នុងគម្ពីរដានីយ៉ែល នោះអ្នកដឹងថានៅក្នុងស្ថានភាពនេះ ព្រះជាម្ចាស់ពិតជាបានរំដោះបុរសដ៏ក្លាហានទាំងបីនាក់អោយមានសេរីភាព ។ នៅពេលដែលអ្នកបានអាននៅជំពូកបន្ទាប់ៗទៀត នោះអ្នកឃើញថា ព្រឹត្តិការណ៍ដ៏អស្ចារ្យនេះពិតជាបានថ្វាយសេរីរុងរឿងដល់ព្រះជាម្ចាស់ ។ នៅពេលណាក៏ដោយ ដែលយើងសូមព្រះជាម្ចាស់អោយធ្វើអ្វី ដែលជាការអស្ចារ្យ យើងត្រូវតែធានាអោយបានច្បាស់ថា គោលបំណងរបស់យើងពិតជាត្រឹមត្រូវ ដែលនឹងថ្វាយសេរីរុងរឿងដល់ព្រះជាម្ចាស់ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវតែច្បាស់នៅក្នុងគំនិតរបស់យើង ដែលថា ព្រះជាម្ចាស់គឺជាម្នាក់ ដែលនឹងធ្វើការសំរេចចិត្តចុងក្រោយ ថាតើទ្រង់នឹងសំដែងការអស្ចារ្យ រឺយើងគ្រាន់តែទូលសូមទ្រង់អោយសំដែងការអស្ចារ្យ ។

មានថ្ងៃមួយព្រះយេស៊ូ និង ពួកសាវ័កបានធ្វើដំណើរទៅកាន់ទីក្រុងយេរ៉ូសាឡឹម ។ ទ្រង់បានបញ្ជូនអ្នកនាំសារមួយចំនួនទៅកាន់ភូមិសាម៉ារី ដើម្បីរៀបចំអ្វីៗអោយរួចរាល់មុនទ្រង់មកដល់ ។ ប្រិតកម្មរបស់ពួកគេបង្ហាញថា ព្រះជាម្ចាស់មានការប្រុងប្រយត្ន័យ៉ាងខ្លាំងអំពី នៅពេលណា ហើយ ហេតុអ្វី បានជាទ្រង់សំដែងការអស្ចារ្យ ។

**លូកា ៩:៥៣-៥៦**

**ប៉ុន្តែអ្នកស្រុកពុំព្រមទទួលព្រះអង្គអោយស្នាក់ឡើយ ព្រោះព្រះអង្គយាងឆ្ពោះទៅក្រុងយេរ៉ូសាឡឹម ពេលសិស្សពីរនាក់ គឺលោកយាកុប និង លោកយ៉ូហានឃើញដូច្នោះក៏ទូលព្រះអង្គថា បពិត្រព្រះអម្ចាស់! តើព្រះអង្គសព្វព្រះហឫទ័យអោយយើងខ្ញុំហៅរន្ទះភ្លើងមកកំទេចអ្នកទាំងនេះឬ? ព្រះយេស៊ូបែរទៅរកគេ ហើយស្តីបន្ទោសគេយ៉ាងខ្លាំង ។ បន្ទាប់មក ព្រះអង្គយាងឆ្ពោះទៅកាន់ភូមិមួយផ្សេងទៀតជាមួយសិស្ស ។**

គោលដៅរបស់គ្រិស្តបរិសទ័ថ្មីៗមិនគួរណារៀនពីអាទច៏កំបាំង ដើម្បីធ្វើការអស្ចារ្យដ៏ធំជារៀងរាល់ថ្ងៃនោះទេ ។ គោលបំណងដ៏ចំបងរបស់យើងគួរតែស្វែងរក នូវអ្វីដែលព្រះជាម្ចាស់ចង់អោយយើងធ្វើនៅថ្ងៃនេះ ហើយបន្ទាប់មក

ធ្វើវាទៅ ។ ជាច្រើនលើកច្រើនសារ ព្រះយេស៊ូបានមានបន្ទូលថា គោលបំណងដ៏ចំបងរបស់ទ្រង់នៅក្នុងជីវិត គឺធ្វើអ្វីដែលព្រះវរបិតាបានប្រាប់ទ្រង់អោយធ្វើ ។

អ្នកអាចប្រាកដច្បាស់ថា ព្រះជាម្ចាស់ចង់អោយយើងម្នាក់ៗខ្លាំងខាងវិញ្ញាណ និង មានចាស់ទុំខាងវិញ្ញាណ ។ អំណាចរបស់ទ្រង់មានសំរាប់យើង ដើម្បីអោយយើងប្រើនៅក្នុងជីវិតប្រចាំថ្ងៃ ។ កុំអោយភ្ញាក់ផ្អើល ប្រសិនបើទ្រង់អនុញ្ញាត្តិអោយបញ្ហាចូលមកក្នុងជីវិតរបស់អ្នក ដើម្បីសាកល្បងភាពអត់ឬត់របស់អ្នក និង ការប្តេជ្ញារបស់អ្នកចំពោះព្រះគ្រិស្ត ។

## ខ. វាត្រូវការចំណាយពេលច្រើនបន្តិច និង ធ្វើការដើម្បីអភិវឌ្ឍអំណាចខាងវិញ្ញាណ

តើមានពេលប៉ុន្មានដង ដែលអ្នកប្រាថ្នាចង់អោយបានក្លាយជាអ្នកលេងកីឡាដ៏ល្អបំផុត ឬក៏ សកម្មភាពណាមួយ? ប្រហែលជាអ្នកស្រមោលស្រមៃចង់ក្លាយជាតារាវាយតែនីស រឺក៏ អ្នកលេងបាល់បោះដ៏ចំណាន រឺក៏ អ្នកលេងបាល់ទាត់ដ៏ពូកែម្នាក់ ។ នៅក្នុងរដូវបាល់ទាល់ពិភពលោក អ្នកចង់មើលកីឡាបាល់ទាត់នោះណាស់ ហើយចង់ក្លាយជាកីឡាករនៅក្នុងព្រឹត្តិការណ៏ ដើម្បីជួយក្រុមនោះអោយមានជ័យជំនះ ។

របៀបដែលមានអំណាចខ្លាំងខាងវិញ្ញាណគឺស្រដៀងគ្នាទៅនឹង វិធីដែលមនុស្សម្នាក់ប្រើដើម្បីអោយរូបគេបានក្លាយទៅអ្នកកីឡាករដ៏ល្បីល្បាញម្នាក់ ។ អ្នកមិនដែលនៅសុខៗក្លាយជាជើងឯករត់ចំងាយដោយចៃដន្យនោះទេ ។ វាបានចំណាយអស់រាប់ពាក់ម៉ោងក្នុងការហ្វឹកហាត់ ដើម្បីអោយអ្នកក្លាយទៅជាជើងឯកក្នុងវិស័យកីឡា ។ នៅពេលដែលអ្នកមើលតារាក្នុងវិស័យកីឡាដែលអ្នកពេញចិត្ត ពួកគេអាចធ្វើវាបានយ៉ាងងាយស្រួល ។ ប៉ុន្តែអ្វីដែលអ្នកមិនបានឃើញនៅកញ្ចក់ទូរទស្សន៏នោះគឺថា ហ្វឹកហាត់អស់រយៈពេលជាច្រើនម៉ោង ។ មានកីឡាករវ័យក្មេងដែលចូលរួមប្រកួតកីឡាអូឡាំពិក បានហ្វឹកហាត់ពី៨ទៅ១០ម៉ោងជារៀងរាល់ថ្ងៃអស់រយៈពេលជាច្រើនឆ្នាំសំរាប់ការប្រកួតនេះ ។

ប្រសិនបើអ្នកនឹងចំណាយពេលមួយចំនួនធំនៅក្នុងការអភិវឌ្ឍន៏អំណាចខាងវិញ្ញាណ ដូចដែលតារាកីឡាទាំងនេះបានធ្វើនៅក្នុងការហ្វឹកហាត់របស់ពួកគេនោះ អ្នកអាចច្បាស់ថា អ្នក និង អ្នកផ្សេងទៀតអាចមើលឃើញយ៉ាងច្បាស់ពីភាពខុសគ្នានៅក្នុងជីវិតរបស់អ្នក ។ កុំរំពឹងគិតថា នឹងក្លាយជាយក្សខាងវិញ្ញាណនៅក្នុងពីរទៅបីសប្តាហ៏នោះឡើយ ។ លោកគ្រូ បីលីក្រាហាំមិនបានក្លាយជាអ្នកសព្វផ្សាយដំណឹងល្អដ៏ល្បីល្បាញ ក្រោយពីទទួលការហ្វឹកហ្វឺនអស់រយៈពេលបីខែនោះទេ ។

ព្រះជាម្ចាស់ត្រៀមជាស្រេចក្នុងការចាប់ផ្តើមធ្វើការនៅក្នុងជីវិតរបស់អ្នកនៅថ្ងៃនេះ ។ ទ្រង់នឹងយកអ្នកនៅត្រង់កន្លែងដែលអ្នកនៅថ្ងៃនេះ ហើយចាប់ផ្តើមដាក់អ្នកអោយឆ្លងកាត់នូវការហ្វឹកហាត់ជាមូលដ្ឋានសិន ។ ព្រះជាម្ចាស់គ្មានផ្លូវកាត់សំរាប់លក់ទំនិញផងដែរ ។

យ៉ាងណាក៏ដោយ កុំរំពឹងអោយព្រះជាម្ចាស់ប្រព្រឹត្តចំពោះអ្នកអោយដូចជាទ្រង់ប្រព្រឹត្តចំពោះអ្នកដ៏ទៃនោះទេ ។ ព្រះជាម្ចាស់មិនចង់អោយធ្វើជា លោកគ្រូ បីលីក្រាហាំទេ ដូច្នេះអ្នកប្រហែលជានឹងមិនមានគ្រប់ទាំងបទពិសោធន៏ដូចលោកគ្រូ បីលីក្រាហាំនោះទេ ។

មានទំហំនៃអំណាចខាងវិញ្ញាណមួយចំនួន អាចកើតមានដោយភាពចាស់ទុំខាងវិញ្ញាណ ។ កុំរំពឹងចង់ក្លាយជារូបមួយនៃការអស្ចារ្យដ៏ធំនៅសប្តាហ៏ក្រោយនោះឡើយ ។ ចំនុចគន្លឹះទៅកាន់ការរីកចំរើនខាងវិញ្ញាណគឺថា អ្នកត្រូវដាក់ភ្នែករបស់អ្នកលើព្រះយេស៊ូនៅថ្ងៃនេះ ។ សូមស្តាប់បង្គាប់ទ្រង់នៅថ្ងៃនេះ នោះទ្រង់នឹងប្រទានអោយអ្នកមានអំណាចខាងវិញ្ញាណដែលអ្នកត្រូវការនៅថ្ងៃនេះ ។ សួរខ្លួនឯង "តើនៅក្នុងផ្នែកណាមួយនៃជីវិតរបស់ខ្ញុំ ដែលព្រះជាម្ចាស់ចង់ចាក់បង្ហូរអំណាចរបស់នៅថ្ងៃនេះ?" ។

សូមធ្វើការប្រៀបធៀបអំណាចខាងវិញ្ញាណទៅនឹងសាច់ដុំនៅក្នុងរូបកាយរបស់អ្នកនៅថ្ងៃនេះ ។ ទំហំ និងកំលាំងនៃសាច់ដុំរបស់អ្នកកំណត់ ថាតើអ្នកមានកំលាំងខ្លាំងប៉ុណ្ណា ។ អ្នកអាចនិយាយថា "ខ្ញុំដឹងថា ខ្ញុំអាចលើទំងន់បានដល់ទៅ២០០គីឡូក្រាមអោយផុតពីក្បាលរបស់ខ្ញុំ" ប៉ុន្តែពាក្យទាំងនោះមិនបានបញ្ជាក់ថាតើអ្នកខ្លាំងប៉ុណ្ណានោះទេ ។ នៅពេលដែលអ្នកលើកដុំដែកមានទំងន់២០០គីឡូក្រាមអោយផុតពីក្បាលរបស់អ្នក ពេលនោះគ្រប់គ្នាដឹងថា អ្នកពិតជាខ្លាំងគ្រប់គ្រាន់អាចលើដុំដែកទំងន់ប៉ុណ្ណោះបានមែន ។ អ្នកមិនអាចមានកំលាំងគ្រប់គ្រាន់ដើម្បីលើកដុំដែកនោះបានដោយនិយាយមកកាន់ខ្លួនឯងជារៀងរាល់យប់ មុនពេលចូលដំណេកថា "ខ្ញុំដឹងថា ខ្ញុំអាចលើកដុំដែកដែលមានទំងន់២០០គីឡូក្រាមអោយផុតពីក្បាលរបស់ខ្ញុំបាន " វាត្រូវចំណាយពេលជាច្រើនដើម្បីហ្វឹកហាត់លើកវា ។

នៅក្នុងវិធីស្រដៀងគ្នានេះដែរ អ្នកមិនអាចអភិវឌ្ឍកំលាំងខាងវិញ្ញាណ ដោយគ្រាន់តែនិយាយមកកាន់ខ្លួនអ្នកថា "ខ្ញុំមានកំលាំងខ្លាំងខាងវិញ្ញាណ ខ្ញុំអាចតទល់នឹងការល្បួងនានា ដែលមកចំពីមុខផ្លូវរបស់ខ្ញុំនៅថ្ងៃនេះ" គ្រាន់តែជាពាក្យសំដីមិនអាចជួយអ្នកអោយចំរើនឡើងខាងវិញ្ញាណនោះបានទេ ។ អ្នកត្រូវតែរីកចំរើនដោយមានជំនួយពីព្រះជាម្ចាស់ ហើយ ទ្រង់នឹងជួយអ្នកអោយបានខ្លាំងខាងវិញ្ញាណ ។ សូមស្តាប់ព្រះជាម្ចាស់ និយាយទៅកាន់ព្រះជាម្ចាស់ ស្តាប់បង្គាប់សេចក្តីបង្រៀនរបស់ទ្រង់ -- គ្រប់កិច្ចការទាំងអស់នេះនឹងជួយអ្នកអោយរីកចំរើនឡើង ។

## គ. ជំហានជាមូលដ្ឋានក្នុងការអភិវឌ្ឍន៍អំណាចខាងវិញ្ញាណ

យើងចាំបាច់ត្រូវប្រុងប្រយត្ន័ថា យើងមិនបង្កើតផ្លូវមួយឆ្ពោះទៅកាន់អំណាចខាងវិញ្ញាណ ដែលស្តាប់ទៅដូចជាសាមញ្ញានោះទេ ។ មានទំហំនៃអំណាចខាងវិញ្ញាណមួយចំនួនកើតមកដែលស្ថិតនៅក្នុងពេលវេលារីកចំរើនដ៏លំបាក ។ គ្មានជំហានទាំង ១០ ដែលអាចក្លាយទៅជាយក្សខាងវិញ្ញាណបានទេ ។ យ៉ាងណាក៏ដោយ អំណាចខាងវិញ្ញាណមិនមែនបំរុងទុកសំរាប់តែមនុស្សជាអ្នកមាននោះទេ ឬក៏ សំរាប់គ្រាន់តែគ្រូអធិប្បាយដ៏ល្បីល្បាញនៅសព្វថ្ងៃនេះដែរ ។ ព្រះជាម្ចាស់ចង់ប្រទានអំណាចរបស់ទ្រង់ដល់គ្រប់អ្នកជឿដ៏ពិតទាំងអស់ មិនខ្វាល់ថាតើពួកគេមានវ័យក្មេង រក៏ ចាស់នោះឡើយ ។

### ១. ក្លាយជាគ្រិស្តបរិសទ័

អំណាចខាងវិញ្ញាណគឺមិនមែនការទទួលខុសត្រូវរបស់ព្រះជាម្ចាស់ទាំងអស់ទេ ឬក៏ ជាអ្វីមួយដែលអ្នកសន្សំបានតាមរយៈអំពើល្អរបស់អ្នកនោះដែរ ។ ជំហានទីមួយដើម្បីមានអំណាចខាងវិញ្ញាណដ៏ពិតប្រាកដគឺជាការជ្រើសរើសក្លាយខ្លួនជាគ្រិស្តបរិសទ័ ។ ប្រសិនបើអ្នកមិនថ្វាយជីវិតរបស់អ្នកទៅកាន់ព្រះយេស៊ូនៅឡើយទេ ហើយមិនទាន់បានសារភាពអំពើបាបរបស់អ្នក ហើយបានសុំទ្រង់អោយអត់ទោសដល់អ្នកនោះទេ ដូច្នេះមិនត្រូវមានការភ្ញាក់ផ្អើលដែលថាទ្រង់មិនបានប្រទានអំណាចខាងវិញ្ញាណណាមួយដល់អ្នក ។

### ២. ខិតទៅជិតព្រះជាម្ចាស់

ជំហានដ៏សំខាន់បំផុតមួយក្នុងការទទួលបានបទពិសោធន៏អំណាចខាងវិញ្ញាណដ៏ពិតនៅក្នុងជីវិតរបស់អ្នកគឺជាការខិតទៅជិតព្រះជាម្ចាស់ ។ នៅពេលដែលព្រះយេស៊ូបានរស់នៅលើផែនដី មានមនុស្សជាច្រើនបានមកកាន់ទ្រង់ដើម្បីសុំអោយទ្រង់ជួយដល់ពួកគេ ។ ពួកគេបានមកកាន់ចំប្រភពដ៏ត្រឹមត្រូវ -- គឺជាបុត្រារបស់ព្រះជាម្ចាស់ ។ ព្រះយេស៊ូគឺពិតជាឧទាហរណ៍ដ៏ល្អបំផុតស្តីពីមនុស្សម្នាក់ ដែលមានអំណាចខាងវិញ្ញាណនៅក្នុងជីវិតរបស់ទ្រង់ ។ ទំនាក់ទំនងរបស់ទ្រង់ជាមួយព្រះជាម្ចាស់ជាព្រះវរបិតា គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះទ្រង់លើរបស់ណាៗទាំងអស់នៅក្នុងពិភពលោកនេះ ។ ប្រសិនបើអ្នកចង់ទទួលបាននូវអំណាចខាងវិញ្ញាណរបស់ព្រះជាម្ចាស់ធ្វើការនៅក្នុងជីវិតរបស់អ្នក ជំហានដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក គឺថាអ្នកត្រូវបន្តចង់ស្គាល់ទ្រង់អោយកាន់ប្រសើរជាងមុនទៀត ។

### ៣. ការស្តាប់បង្គាប់

អ្នកមានការទទួលខុសត្រូវដ៏សំខាន់មួយ ដើម្បីបំពេញផ្នែករបស់អ្នកនៅក្នុងការអភិវឌ្ឍន៏អំណាចខាងវិញ្ញាណ នៅក្នុងជីវិតរបស់អ្នក ។ យើងក៏បានបញ្ជាក់រួចមកហើយដែរនូវជំហ៊ានដ៏ជាមូលដ្ឋានពីរ -- ការក្លាយជាគ្រិស្តបរិសទ័ ហើយការខិតទៅជិតព្រះជាម្ចាស់ ។ ការស្តាប់បង្គាប់គឺជាជំហានមួយផ្សេងទៀតដ៏សំខាន់នៅក្នុងរីកចំរើនខាងវិញ្ញាណ ។ ក្រិតវិន័យរបស់ព្រះជាម្ចាស់ច្បាស់លាស់ណាស់ ជាពិសេសក្រិតវិន័យទាំងពីរដ៏សំខាន់បំផុតរបស់ព្រះជាម្ចាស់នៅក្នុង ព្រះគម្ពីរ ។ ស្រលាញ់ព្រះជាម្ចាស់ និង ស្រលាញ់អ្នកជិតខាងរបស់អ្នកដូចខ្លួនឯង ។ នៅពេលដែលអ្នកស្វែងរកនូវការ យល់ដឹងក្រិតវិន័យរបស់ព្រះជាម្ចាស់ ហើយប្រើក្រិតវិន័យនោះនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់អ្នក នោះអ្នកនឹងរក ឃើញការសំខាន់ៗដ៏ស៊ីជុំរៅនៅក្នុងជីវិតរបស់អ្នក ស្តីពីរបៀបខិតទៅជិតព្រះជាម្ចាស់ ។

## ៤. រៀបចំខ្លួនរបស់អ្នកដើម្បីទទួលអំណាចខាងវិញ្ញាណរបស់ព្រះជាម្ចាស់

ប្រសិនបើអ្នកចង់ទទួលបានអំណាចខាងវិញ្ញាណ នោះអ្នកត្រូវតែរៀបចំខ្លួនរបស់អ្នកដើម្បីទទួលវា ។ វិធី មួយនៅក្នុងការធ្វើបែបនេះ គឺតាមរយៈការសិក្សាព្រះគម្ពីរ ។ អ្នកត្រូវតែយល់ដឹង និង ជឿនូវអ្វីដែលព្រះគម្ពីរថែងអំពី អំណាចខាងវិញ្ញាណ និង ជំនឿរបស់ព្រះជាម្ចាស់ ។ អ្វីដែលជាសេចក្តីពិតនៃការទទួលបាននូវអំណាចខាងវិញ្ញាណ ជាទូ ទៅក៏អាចយកមកអនុវត្តបាននៅក្នុងជីវិតដែលដើរក្នុងសេចក្តីជំនឿរបស់ព្រះជាម្ចាស់ ។

មានមនុស្សជាច្រើនមិនបានទទួលសេចក្តីជំនឿពីព្រះជាម្ចាស់ ដោយព្រោះពួកគេមិនបានដឹងអ្វីទៅជាសេចក្តី ជំនឿ របៀបទទួលបានវា និង របៀបក្នុងការប្រើប្រាស់វា ។ ពួកគេគិតថា ជំនឿវាដូចតែគ្នាទៅនឹងការជឿនោះដែរ ។ ប្រសិនបើពួកគេប្រាប់ខ្លួនឯងថា ពួកគេមានវា -- ដែលជំនឿកើតមានឡើង ។ ប៉ុន្តែនោះមិនមែនជាអ្វីដែលព្រះគម្ពីរ បង្រៀនទេ ។ អ្នកត្រូវតែស្វែងរកនូវអ្វីដែលព្រះគម្ពីរបង្រៀនអំពីជំនឿ និង របៀបទទួលបានវា និង របៀបប្រើប្រាស់ វាអោយមានប្រសិទ្ធិភាព ។

អ្នកប្រហែលជាធ្លាប់បានឃើញព្រះជាម្ចាស់ប្រើមិត្តភ័ក្តិរបស់អ្នកនៅក្នុងវិធីមួយដ៏ពិសេស ។ អ្នកនិយាយថា នោះមើលទៅ គួរអោយអស្ចារ្យណាស់ ។ ខ្ញុំគិតថា ខ្ញុំចង់ក្លាយជាអ្នកផ្សព្វផ្សាយដំណឹងល្អដ៏អស្ចារ្យម្នាក់ផងដែរ ។ ប៉ុន្តែ តើការនោះពិតជាអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើមែនឬទេ? ព្រះជាម្ចាស់មានគំរោងការសំរាប់អ្នក ទ្រង់មានកិច្ច ការសំរាប់ដើម្បីអោយអ្នកធ្វើ ។ ជំហានមួយដ៏មានសារៈសំខាន់បំផុតនៅក្នុងការរីកចំរើនឡើងនៅក្នុងអំណាចរបស់ ព្រះជាម្ចាស់គឺត្រូវបន្តស្តាប់ នូវអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើជារៀងរាល់ថ្ងៃ ។ សុំកុំអង្គុយរងចាំទទួលបាននូវ ទីសំគាល់ដ៏ពិសេសមកពីព្រះជាម្ចាស់ មុនពេលអ្នកធ្វើអ្វីផ្សេងទៀតនៅថ្ងៃនេះ ។ ប៉ុន្តែនៅពេលដែលអ្នកបន្តស្មោះត្រង់

ជាមួយនឹងការទទួលខុសត្រូវប្រចាំថ្ងៃរបស់អ្នក នោះត្រូវចំណាយពេលនិយាយទៅកាន់ព្រះជាម្ចាស់ ហើយ សុំទ្រង់ពីរបៀបដែលអ្នកអាចធ្វើអោយបានប្រសើរនៅក្នុងកិច្ចការដែលអ្នកធ្វើ ។

## ៥. ការអធិស្ឋាន

អ្នកត្រូវតែអធិស្ឋាន ហើយ សុំអោយព្រះជាម្ចាស់ប្រទានអំណាចខាងវិញ្ញាណដល់អ្នក ។ មានគ្រិស្តបរិសទ័មួយចំនួនមានពេលវេលាដ៏លំបាកក្នុងការនិយាយទៅកាន់ព្រះជាម្ចាស់ នៅពេលដែលពួកគេអធិស្ឋាន ។ ប្រសិនបើអ្នកមានបញ្ហានេះ មុនពេលអ្នកចាប់ផ្តើមអធិស្ឋាន សូមបង្កើតនូវតារាងមួយស្តីពីការល្បួងនានា និង បញ្ហាផ្សេងៗ ដែលបានជួបប្រទះនៅថ្ងៃនេះ ។ មួយវិញទៀតសរសេរចុះនូវអ្វីដែលជាកិច្ចការល្អផ្សេងៗបានកើតឡើងនៅថ្ងៃនោះផងដែរ ។ បន្ទាប់មកសូមសរសេរចុះនូវបញ្ហាផ្សេងៗ និង ស្ថានភាពលំបាកៗដែលអ្នកគិតថា នឹងប្រឈមមុខជាមួយនឹងអ្នកពេលនៅថ្ងៃនោះ រឺក៏ថ្ងៃស្អែក ។

ចាប់ផ្តើមការអធិស្ឋានរបស់អ្នកដោយការអរគុណព្រះជាម្ចាស់សំរាប់ការជួយដល់អ្នក ដែលបានកើតឡើងនៅថ្ងៃនេះ ។ "រងចាំងមួយភ្លែតសិន" អ្នកនិយាយថា "តើខ្ញុំដឹងដោយរបៀបណាដែលថា ព្រះជាម្ចាស់ទទួលខុសត្រូវរាល់ការល្អៗទាំងអស់ ដែលបានកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំនៅថ្ងៃនេះ?" អ្នកអាចសរសេរវាជាសេចក្តីសង្ខេប រឺក៏អរគុណព្រះជាម្ចាស់សំរាប់ផែនការរបស់ទ្រង់ ដែលនាំមកនូវការល្អគ្រប់យ៉ាងចូលមកក្នុងជីវិតរបស់អ្នកនៅថ្ងៃនេះ ។

បន្ទាប់មកចំណាយពេលអ្នកអធិស្ឋានសំរាប់បញ្ហា ដែលមាននៅក្នុងបញ្ជីរបស់អ្នក ។ សុំព្រះជាម្ចាស់អោយជួយអ្នកស្វែងយល់នូវអ្វីដែលអ្នកអាចធ្វើបាន ដើម្បីឆ្លើយតបទៅនឹងបញ្ហានីមួយៗនៅក្នុងវិធីមួយដែលផ្គាប់ចិត្តដល់ព្រះជាម្ចាស់ ។ សូមព្យាយាមគិតអំពីខគម្ពីរផ្សេងៗដែលស៊ីទៅនឹងស្ថាននោះ ។ សុំព្រះជាម្ចាស់អោយប្រទាននូវអំណាចដល់អ្នក ដើម្បីអោយអ្នកអាចតតាំងទៅនឹងការល្បួងនានាដែលចង់នាំអ្នកអោយប្រព្រឹត្តអំពើបាប ។ កុំសុំព្រះជាម្ចាស់នូវអំណាចខាងវិញ្ញាណ ដើម្បីធ្វើសង្គ្រាមជាមួយនឹងបញ្ហាផ្សេងៗ ដែលអ្នករំពឹងថា អ្នកនឹងប្រឈមមុខ១០ក្រោយចាប់ពីពេលឥឡូវទៅ ។ ដាក់ការយកចិត្តទុកដាក់របស់សំរាប់តែនាពេលបច្ចុប្បន្ន ហើយសំរាប់នាពេលអនាគតដ៏ខ្លីខាងមុខបានហើយ ។

## ៦. រៀនពីការសាកល្បង និង បញ្ហាផ្សេងរបស់អ្នក

ការអធិស្ឋានមិនមែនជាចុងបញ្ចប់នៃការទទួលខុសត្រូវរបស់អ្នក នៅក្នុងការអភិវឌ្ឍន៍អំណាចខាងវិញ្ញាណនោះទេ ។ យ៉ាកុប ១:២-៤ បញ្ជាក់យ៉ាងច្បាស់ថា ព្រះជាម្ចាស់នឹងបញ្ជូនការសាកល្បងគ្រប់ប្រភេទចូលមកក្នុងជីវិត

របស់អ្នក ដើម្បីសាកល្បងយើង ហើយផ្តល់ឱកាសដល់យើងដើម្បីអភិវឌ្ឍភាពអត់ឃ្មត់ និង លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ។ យើងត្រូវតែយកអ្វីដែលព្រះគម្ពីរបង្រៀន រឺក៏ តាមរយៈគ្រិស្តបរិសទ័ផ្សេងៗក្តីមកអនុវត្ត ។ ជារៀងរាល់ថ្ងៃអ្នកនឹងប្រឈមមុខនឹងការសំរេចចិត្តនានា ។

**យ៉ាកុប ១:២-៤**

**បងប្អូនអើយ ទុកួលំបាកគ្រប់យ៉ាងដែលបងប្អូនត្រូវឆ្លងកាត់នោះ សូមចាត់ទុកថាជាការដែលធ្វើអោយបងប្អូនមានអំណរដ៏បរិបូណ៌វិញ ដោយដឹងថាការល្បងលមើលជំនឿរបស់បងប្អូននឹងនាំអោយបងប្អូនចេះស៊ូទ្រាំ ។ ក៏ប៉ុន្តែត្រូវអោយការស៊ូទ្រាំនេះបង្កើតចេញជាផលដ៏ល្អគ្រប់លក្ខណៈ ដើម្បីអោយបងប្អូនបានគ្រប់លក្ខណៈ មានគុណសម្បត្តិល្អសព្វគ្រប់ ឥតខ្វះត្រង់ណាឡើយ ។**

នៅពេលដែលអ្នកមានភាពចាស់ទុំខាងវិញ្ញាណនៅក្នុងសេចក្តីជំនឿគ្រិស្តបរិសទ័ អ្នកត្រូវតែអភិវឌ្ឍនូវការយល់ដឹងដ៏ច្បាស់លាស់មួយនៃស្ថានភាពអ្វីជាអំណាចដ៏ពិតប្រាកដខាងវិញ្ញាណ ។ អ្នកមិនមែនជាតុក្កតារបស់ព្រះជាម្ចាស់ទេ ។ ទ្រង់សំឡឹងមកអ្នកចាត់ទុកអ្នកថាជាកូនរបស់ទ្រង់ ។ ទ្រង់រំពឹងពីអ្នក ដើម្បីអោយអ្នកអភិវឌ្ឍអោយក្លាយជាគ្រិស្តបរិសទ័ពេញវ័យក្នុងការចេះដោះស្រាយ និង ទទួលខុសត្រូវខ្ពស់ ។ ផ្នែកមួយនៃដំណើរការក្នុងការក្លាយជាគ្រិស្តបរិសទ័ពេញវ័យគឺត្រូវស្វែងយល់ពីលក្ខណៈសម្បត្តិនៃអត្តចរិត ។ យើងត្រូវរៀនអោយចេះវិភាគថាតើមួយណាជាអំណាចរបស់ព្រះជាម្ចាស់ និង មួយណាជាអំណាចរបស់មារសាតាំង ។

# ជំពូកទី៤
# អំណាចខាងវិញ្ញាណដ៏ពិតទល់នឹងអំណាចនៃការក្លែងបន្លំ

## ក. អំណាចរបស់ព្រះជាម្ចាស់ ទល់នឹង អំណាចរបស់មារសាតាំង ទល់នឹង អំណាចមនុស្ស

### ១. អ្នកត្រូវតែជ្រើសរើសចៅហ្វាយនៅលើជីវិតរបស់អ្នក

ព្រះគម្ពីរមានដំណឹងមួយចំនួនដែលថា មានអ្នកមិនមែនជាគ្រិស្តបរិសទ័ភាគច្រើនមិនបានលឺ ។ បើទោះបីជាពួកគេធ្លាប់បានលឺក៏ដោយ ក៏នៅមានមនុស្សភាគច្រើនសើចចំអកដាក់អោយអំពីការនោះ ។ ព្រះគម្ពីរថែងថា គ្រប់មនុស្សម្នាក់ៗគឺជាទាសករ ។ ពួកគេនឹងនិយាយថាអ្នកគឺ "ជាមនុស្សឆ្កួតហើយ" ហើយពួកគេក៏បាននិយាយទៀតថា "ខ្ញុំគឺជាមនុស្សដែលមានសេរីភាព" ។ ប៉ុន្តែប្រជាប្រិយភាពចំពោះកិច្ចការនេះ មិនបានផ្លាស់ប្តូរនូវសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ។

**រ៉ូម ៦:១៦-១៨**

**បងប្អូនមិនដឹងទេឬ បើបងប្អូនប្រគល់ខ្លួនទៅបំរើ និង ស្តាប់បង្គាប់ម្ចាស់ណា បងប្អូននឹងក្លាយទៅជាខ្ញុំបំរើរបស់អ្នកដែលបងប្អូនស្តាប់បង្គាប់នោះ ឬ មួយបងប្អូននឹងទៅជាខ្ញុំបំរើរបស់បាប ដែលនាំអោយបងប្អូនស្លាប់ ឬមួយបងប្អូនស្តាប់បង្គាប់ព្រះជាម្ចាស់ដែលនាំអោយបងប្អូនបានសុចរិត ។ សូមអរព្រះគុណព្រះជាម្ចាស់ពីដើម បងប្អូនជាខ្ញុំបំរើរបស់បាបមែន តែដោយបងប្អូនបានស្តាប់បង្គាប់យ៉ាងស្មោះអស់ពីចិត្តតាមគោលការណ៍ នៃសេចក្តីបង្រៀនដែលបងប្អូនបានទទួល បងប្អូនក៏បានរួចពីអំណាចបាប មកបំរើសេចក្តីសុចរិតវិញ ។**

ការជ្រើសរើសពិតជាត្រូវធ្វើមែន -- មានន័យថា អ្នកត្រូវជ្រើសរើសមានសេរីភាពបំរើព្រះជាម្ចាស់ រឺក៏ មារសាតាំង ។ ប៉ុន្តែគ្មានជំរើសទីបីទេ ។ អ្នកមិនអាចនិយាយថា "ខ្ញុំមិនចង់បានព្រះជាម្ចាស់ រឺក៏ មារសាតាំងធ្វើជាចៅហ្វាយរបស់ខ្ញុំទេ ។ ខ្ញុំចង់ធ្វើជាចៅហ្វាយលើខ្លួនឯងវិញ " ។ ប្រសិនបើអ្នកជ្រើសរើសបដិសេធន៏ព្រះជាម្ចាស់ នោះអ្នកនឹងជ្រើសរើសមារសាតាំងធ្វើជាចៅហ្វាយដោយស្វ័យប្រវត្តិជាអ្នកដឹកនាំលើជីវិតរបស់អ្នកជាមិនខាន ។ នៅក្នុងគម្ពីរ

សញ្ញាចាស់ លោកយ៉ូស្វេ ដែលជាអ្នកដឹកនាំលើប្រជាជាតិអ៊ីស្រាអែល ក៏បានផ្តល់ការជ្រើសរើសបែបដុំរុញនេះដែរដល់ពួកគេ ។ គាត់បានបញ្ជាដល់ពួកអ៊ីស្រាអែលថា សូមជ្រើសរើសថាតើនរណាដែលអ្នកនឹងបំរើ ។ អ្នករាល់នឹងជ្រើសរើសបំរើព្រះជាម្ចាស់ រឺមួយក៏ជ្រើសរើសបំរើព្រះដ៏ទៃ ។ លោកយ៉ូស្វេបាននិយាយថា "ចំណែកឯគ្រួសារខ្ញុំ និងខ្ញុំ យើងនឹងបំរើព្រះជាម្ចាស់ជារៀងរហូត" (យ៉ូស្វេ ២៤:១៥) ។

សូមស្រមោលស្រមៃមើលមួយភ្លែតសិនថា អ្នកអុំទូកនៅក្នុងទន្លេមួយ ហើយអ្នកមានចង្វាតែមួយ ។ អ្នកព្យាយាមអុំ ទូកនោះដោយខ្លួនឯង ប៉ុន្តែទូកនោះនឹងវិញនៅជុំវិញជាមិនខានដោយព្រោះអ្នកមានតែចង្វាមួយ ។ ចង្វាមួយនៅឯមាត់ទន្លេ ។ ព្រះយេស៊ូ និង មារសាតាំងកំពុងតែឈរនៅមាត់ទន្លេម្ខាងនោះ ។ អ្នកអាចជ្រើសរើសនរណាម្នាក់នឹងអាច ឡើងជិះទូកជាមួយអ្នក ។ ប្រសិនបើអ្នកជ្រើសរើសមារសាតាំងធ្វើជាដៃគូរបស់អ្នក វានឹងនាំអ្នកទៅតាមផ្លូវរបស់វាតែប៉ុណ្ណោះ -- គឺចុះជ្រោះ ។ វាជាការងាយស្រួលណាស់ក្នុងការអុំទូកអោយធ្លាក់ចុះជ្រោះ ប៉ុន្តែមានគ្រោះថ្នាក់មួយចំនួនធំ ដែលមានដុំថ្មនៅក្នុងជ្រោះនោះ ។

ប្រសិនបើអ្នកជ្រើសរើសព្រះជាម្ចាស់ធ្វើជាដៃគូអុំទូករបស់អ្នក នោះទ្រង់នឹងព្យាយាមប្រាប់អ្នកអោយទៅតាមផ្លូវរបស់ទ្រង់ -- គឺឡើងទៅត្រើយម្ខាងវិញ ។ វាប្រហែលជាមានការលំបាកបន្តិចក្នុងការអុំឡើងទៅម្ខាងនៃទន្លេ ប៉ុន្តែជាមួយព្រះជាម្ចាស់ជាដៃគូរបស់អ្នក អ្នកអាចច្បាស់ថា ទ្រង់នឹងមិនធ្វើអោយអ្នកបរាជ័យនោះទេ ។

មាននរណាម្នាក់ត្រូវតែកាច់ចង្កូតទូកដើម្បីបញ្ចៀសគ្រោះថ្នាក់នានា ។ ប្រសិនបើអ្នកអនុញ្ញាត្តិអោយព្រះជាម្ចាស់កាច់ចង្កូតទូក នោះទ្រង់នឹងធ្វើបានយ៉ាងល្អឥតខ្ចោះ ដោយព្រោះទ្រង់មានបទពិសោធន៏ក្នុងកាច់ចង្កូតច្រើនជាងអ្នកទៅទៀត ។ ប៉ុន្តែប្រសិនបើអ្នកចចេះចង់កាច់ចង្កូតវិញ នោះអ្នកប្រហែលជាអាចបុកទូកនេះទៅនឹងថ្ម បើទោះជាព្រះជាម្ចាស់គង់នៅក្នុងទូកនោះក៏ដោយ ។

ប្រសិនបើអ្នកបានជ្រើសរើសព្រះយេស៊ូជាព្រះអម្ចាស់ និង ជាចៅហ្វាយរបស់អ្នក នោះអ្នកអាចប្រាកដថា ព្រះជាម្ចាស់ចង់អោយអ្នកទទួលបានការដ៏ប្រសើរបំផុត ។ ប៉ុន្តែកុំអោយមានការភ្ញាក់ផ្អើល នៅពេលណាមានការល្បួងអោយប្រព្រឹត្តអំពើបាបមកកាត់ផ្លូវរបស់អ្នក ។ មារសាតាំងកម្រនឹងមកដោយកាន់ទង់ជ័យក្រហមបក់ដាក់អ្នក ហើយនិយាយសួរស្តីសំលាញ់! ខ្ញុំគឺជាមារសាតាំង ហើយខ្ញុំមកទីនេះដើម្បីធ្វើអោយអ្នកប្រព្រឹត្តអំពើបាប ។ មានគ្រិស្តបរិសទ័ជាច្រើនមានពេលវេលាដ៏លំបាកក្នុងចែកអោយដាច់ពីភាពផ្សេងគ្នារវាង សំលេងរបស់ព្រះជាម្ចាស់ និង សំលេងរបស់

មារសាតាំង ។ នៅត្រង់នេះដែលធ្វើអោយមានការភ័ណច្រឡំ ដោយព្រោះសំលេងទាំងពីរនេះនិយាយមកកាន់យើង តាមរយៈការគិតរបស់យើង ។

មានគោលការណ៏ណែនាំមួយចំនួននៅក្នុងព្រះគម្ពីរ ដែលអាចជួយយើងដឹងថាតើការគិតនោះមកពីព្រះជាម្ចាស់ រឺពីមារសាតាំង ។

(១) ព្រះជាម្ចាស់នឹងមិនដែលអោយអ្នកធ្វើទៅលើក្រិតវិន័យរបស់ទ្រង់ សូម្បីតែមួយនោះឡើយ

(២) មារសាតាំងនឹងព្យាយាមធ្វើអោយអ្នកយកសេចក្តីពិតមួយ ក្នុងចំណោមសេចក្តីពិតផ្សេងៗទៀតរបស់ព្រះជាម្ចាស់ ហើយអនុវត្តវានៅក្នុងជីវិតរបស់អ្នកនៅក្នុងវិធីមួយ ដែលវាអាចប្រព្រឹត្តខុសទៅនឹងវិន័យមួយផ្សេងទៀតរបស់ព្រះជាម្ចាស់ ។ ឧទាហរណ៏ មារសាតាំងនឹងដាក់ការគិតនៅក្នុងចិត្តគំនិតរបស់អ្នកថា "ព្រះគម្ពីរចែងថា អោយនិយាយតែពីសេចក្តីពិត ។ សូមប្រាប់គ្រប់គ្នានៅក្នុងផ្ទះថា អ្នកបានឃើញ វិបុលលួចលុយខ្លះពីហោរប៉ៅរបស់អ្នក ។ ប្រសិនបើអ្នកពិតជាស្តាប់បង្គាប់តាមការគិតនេះមែន នោះអ្នកនឹងរំលោភខគម្ពីរផ្សេងៗទៀតដូចមានចែងនៅក្នុង អេភេសូ ៤:១៥ ដែលចែងថា ត្រូវនិយាយសេចក្តីពិតដោយ**<u>សេចក្តីស្រលាញ់</u>** នៅក្នុងម៉ាថាយ ១៨:១៥-១៧ ផ្តល់អោយនូវការណែនាំដ៏ច្បាស់លាស់ស្តីពីរបៀបឆ្លើយតប ប្រសិនបើមាននរណាម្នាក់ប្រព្រឹត្តអំពើបាបប្រឆាំងទាស់នឹងអ្នក ។

## ២. តើអំណាចរបស់មារសាតាំងមានពិតប្រាកដដែរឬទេ?

វាមិនមែនជាការលំបាកទេក្នុងការជឿថា ព្រះជាម្ចាស់មានអំណាចដ៏ខ្លាំងពូកែដាច់គេ ។ ប៉ុន្តែចុះមារសាតាំងវិញយ៉ាងណាដែរ? តើសព្វថ្ងៃនេះ មារសាតាំងពិតជាមានអំណាចដែរឬទេ? ព្រះគម្ពីរចែងថា វាគឺជាឪពុកនៃ អ្នកកុហក ។ តើវាចង់អោយយើងជឿជាក់ថា វាមានអំណាចដ៏ខ្លាំងពូកែដែរឬទេ? ព្រះគម្ពីរបញ្ជាក់យ៉ាង ច្បាស់ថា អំណាចរបស់មារសាតាំងពិតជាមានមែន ហើយកំពុងតែមានសកម្មភាពយ៉ាងខ្លាំងនៅក្នុងពិភព លោកនាសព្វថ្ងៃនេះ ។

**អេភេសូ ៦:១០-១៣**

**មួយវិញទៀត ចូរទាញយកកំលាំងដោយរួមជាមួយព្រះអម្ចាស់ និង ដោយសារព្រះចេស្តាដ៏ខ្លាំងក្លារបស់ព្រះអង្គ ។ ចូរបងប្អូនប្រដាប់ខ្លួនដោយគ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ។ ដើម្បីអាចតតាំងនឹងកលល្បិចរបស់មារ ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សទេ គឺតយុទ្ធទល់នឹងវត្ថុសក្តិសិទ្ធិទល់នឹងអ្វីៗដែលមានអំណាច ហើយតយុទ្ធទល់នឹងឥទ្ធិពលអរូបិយដ៏អាក្រក់ទាំងឡាយ**

**ដែលមាននៅស្ថានលើដែរ ។ ហេតុនេះ ចូរបងប្អូនប្រើគ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ទៅ ដើម្បីអោយបងប្អូនអាចតទល់នៅថ្ងៃអពមង្គល ហើយមានជំហររឹងប៉ឹងដែល ដោយបានប្រើគ្រប់មធ្យោបាយ ។**

នៅក្នុងខគម្ពីរទាំងនេះបង្ហាញថា កងកំលាំងនៃពួកវិញ្ញាណអាក្រក់ពិតជាមានមែននៅក្នុងពិភពលោកនេះ ប៉ុន្តែយើងមិនចាំបាច់ភ័យខ្លាចពួកវាឡើយ ប្រសិនបើយើងពឹងផ្អែកលើអំណាចដ៏ខ្លាំងពូកែរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងយើង ។ នៅពេលដែលមារសាតាំងបានល្បួងព្រះយេស៊ូនៅឯវាលរហោស្ថាន ព្រះយេស៊ូមិនបានភ័យខ្លាចចំពោះមារសាតាំងឡើយ ហើយទ្រង់ថែមទាំងបានបដិសេធន៏នូវវត្តមានរបស់មារថែមទៀតផង ។ ទ្រង់បានជឿជាក់លើព្រះជាម្ចាស់យ៉ាងពិតប្រាកដ ហើយបានឆ្លើយតបទៅការល្បួងរបស់មារសាតាំងវិញ ដោយស្រង់ខគម្ពីរផ្សេងៗចេញពីព្រះគម្ពីរ ។ មានពេលវេលាជាច្រើន ដែលព្រះយេស៊ូដេញអារក្សចេញពីមនុស្ស ។

ព្រះគម្ពីរព្រមានយើងអោយមានការប្រុងប្រយត្ន័ និង ភ្ញាក់ស្មារតីជានិច្ចទៅនឹងការវាយប្រហារផ្សេងៗរបស់មារសាតាំង ។ ព្រះគម្ពីរហៅមារសាតាំងថាជា ឪពុកនៃអ្នកកុហក ។ វាមានជំនាញដ៏ប៉ុណប្រសព្វក្នុងការបោកបញ្ឆោតមនុស្ស ។ ទាំងគ្រិស្តបរិសទ័ និង មិនមែនជាគ្រិស្តបរិសទ័អាចជាជនរងគ្រោះដោយសារការបោកបញ្ឆោតនេះ ។ ប្រសិនបើអ្នកបានជ្រើសរើសដើរតាមព្រះគ្រិស្ត នោះមារសាតាំងមានគោលដៅមួយដើម្បីបំផ្លាញអ្នក ។ វាចង់បំផ្លាញទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់ ។ វាមិនខ្វល់ថា វានឹងធ្វើយ៉ាងក៏ដោយ ។

**១ ពេត្រុស ៥:៨_៩**

**ត្រូវភ្ញាក់ខ្លួន ហើយ ប្រុងស្មារតីជានិច្ច! ដ្បិតមារជាសត្រូវនឹងបងប្អូនកំពុងតែក្រវែលជុំវិញបងប្អូនដូចសឹង្ហក្រវែលទាំងគ្រហឹម រកត្របាក់ស៊ីអ្នកណាម្នាក់ ។ ចូរប្រឆាំងនឹងវា ហើយមានជំនឿមាំមួនឡើង ដោយដឹងថា បងប្អូនរួមជំនឿឯទៀតៗនៅក្នុងសកលលោកទាំងមូលក៏ត្រូវរងទុក្ខលំបាកដូចបងប្អូនដែរ ។**

វាគួរអោយចាប់អារម្មណ៏ណាស់នៅក្នុងកត់សំគាល់ថា មានអត្ថបទខគម្ពីរជាច្រើន ដែលនិយាយអំពីមារសាតាំង ហើយក៏ផ្តល់អោយផងដែរនូវពាក្យនៃការលើកទឹកចិត្តអំពីវិធី ដែលយើងអាចយកឈ្នះលើការវាយ ប្រហារនានារបស់មារសាតាំងបាន ។ យើងមិនអាចយកឈ្នះលើមារសាតាំងដោយកំលាំងរបស់យើងនោះទេ ។ យើងត្រូវតែពឹងផ្អែកលើជំនួយ និង អំណាចរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងយើង ។ ប៉ុន្តែយើងអាចប្រឈមមុខជារៀងរាល់ថ្ងៃ

ដោយមានទំនុកចិត្តលើទ្រង់ ។ ព្រះជាម្ចាស់គង់នៅក្នុងយើង ហើយ អំណាចរបស់ទ្រង់ខ្លាំងជាងអ្វីៗផ្សេងៗទៀត ដែលមារសាតាំងចង់យកមកដាក់នៅក្នុងជីវិតរបស់យើង ។

មារសាតាំងស្រលាញ់ចង់ធ្វើអោយមនុស្សធ្លាក់ខ្លួនជាទាសករនៃអំពើបាប ។ ព្រះគម្ពីរផ្តល់អោយនូវការព្រមានយ៉ាងច្បាស់លាស់ថា អោយយើងនៅអោយឆ្ងាយពីអន្ទាក់របស់មារសាតាំង ។ តាមរយៈការបោកបញ្ឆោត និង អំណាចដ៏ខ្លាំងរបស់មារ វាព្យាយាមដាក់អន្ទាក់មនុស្សអោយទៅកាន់គោលលទ្ធិក្លែងក្លាយ និង ជឿលើហោរសាស្រ្តក្លែងក្លាយនានា ។ ការទាយជោគជតាដោយអាស្រ័យដារាសាស្ត្រគឺអន្ទាក់មួយក្នុងចំណោមអន្ទាក់ជាច្រើនរបស់វា ។ អស់អ្នកណាដែលជឿលើការបង្រៀននេះថា អ្វីៗទាំងអស់ដែលអ្នកមានពិសោធន៏គឺត្រូវបានត្រួតត្រាដោយហ្វូងដារា ហើយ ការចក្ររាសីរបស់អ្នក ។

ការនេះពិតជាខុសឆ្គងទៅនឹងអ្វីដែលព្រះគម្ពីរបង្រៀនស្តីពីពិភពលោករបស់យើង ។ ព្រះជាម្ចាស់គឺជាម្នាក់ដែលគ្រប់គ្រងលើសកលលោកនេះទាំងមូល មិនមែនដួងតារា រឺក៏ ជោគជាតារាសីឡើយ ។ ពិតណាស់ ព្រះជាម្ចាស់អាចគ្រប់គ្រងលើជីវិតរបស់អ្នកបាន ប្រសិនបើទ្រង់ជ្រើសរើសនោះ -- ជាជាងអោយអ្នកជ្រើសរើសអនុញ្ញាត្តិអោយទ្រង់គ្រប់គ្រង ។ ការទាយជោគជតាដោយអាស្រ័យតារាសាស្ត្រដាក់អន្ទាក់អ្នកអោយធ្លាក់ទៅក្នុងការភ័យខ្លាច អោយអ្នកមានចំងល់ថាតើវានឹងកើតឡើងយ៉ាងដូច្នេះមែនឬ? ។

## ៣. អំណាចរបស់មនុស្ស

អំណាចរបស់ព្រះជាម្ចាស់មានពិតប្រាកដមែន ហើយអំណាចរបស់មារសាតាំងក៏មានពិតប្រាកដដែរ ។ ប៉ុន្តែក៏មាននូវប្រភពអំណាចមួយផ្សេងទៀតដែរគឺ -- អំណាចរវាងមនុស្សនិងមនុស្ស ។ យើងមិនមែនជាតុក្កា ដែលមានខ្សែ ហើយត្រូវបានញាក់ដោយព្រះជាម្ចាស់ រឺក៏ មារសាតាំងនោះទេ ។ ព្រះជាម្ចាស់បានបង្កើតយើងមកអោយមានសមត្ថភាពអាចធ្វើគ្រប់កិច្ចការជាច្រើន ដោយមិនត្រូវការជំនួយពីមារសាតាំង រឺ ព្រះជាម្ចាស់នោះទេ ។ គំនិតរបស់មនុស្សក៏មានអំណាចដ៏ខ្លាំងផងដែរ ។ មានមនុស្សជាច្រើនអាចធ្វើអោយខ្លួនរបស់ពួកគេឈឺ ដោយការព្រួយបារម្ភអំពីការនោះ ហើយគិតតែអំពីការឈឺ ។ គំនិតរបស់មនុស្សអាចនាំមនុស្សម្នាក់ធ្លាក់ទៅក្នុងភាពថប់អារម្មណ៏ ដែលនោះធ្វើអោយអ្នកមានការអស់កំលាំងគ្រប់ពេល -- រឺក៏ថែមទាំងបានគិតអំពីការស្លាប់ខ្លួនឯង ។

មានគ្រិស្តបរិសទ័ជាច្រើនស្តីបន្ទោសមារសាតាំងចំពោះការល្បួងនានាដែលនាំអោយប្រព្រឹត្តអំពើបាប ។ ជាការពិតណាស់ មារសាតាំងជារឿយៗគឺជាម្នាក់ដែលល្បួងយើង ។ ប៉ុន្តែក៏មានពេលជាច្រើនផងដែរ ដែលយើងជ្រើសរើសគិតអំពើទង្វើបាបផ្សេងៗ ហើយនាំការល្បួងមកធ្លាក់លើខ្លួនយើង ។ អ្វីដែលមារសាតាំងធ្វើគឺថា អង្គុយលើកៅអីហើយស្រែកលើកទឹកចិត្តអោយអ្នកធ្វើវា ។

ព្រះបន្ទូលបញ្ជាក់យ៉ាងច្បាស់នៅក្នុងព្រះគម្ពីរទាំងមូល -- មានមនុស្សមានអំណាចក្នុងការជ្រើសរើសដើម្បីប្រព្រឹត្តអំពើល្អ ឬក៏ ប្រព្រឹត្តអំពើអាក្រក់ ។ ប្រសិនបើអ្នកជ្រើសរើសប្រព្រឹត្តអំពើអាក្រក់ នោះមារសាតាំងរងចាំនៅឯមាត់ទ្វារជាស្រេចដើម្បីជួយអ្នក ។ ប្រសិនបើអ្នកជ្រើសរើសប្រព្រឹត្តអំពើល្អ នោះអ្នកនឹងត្រូវការជំនួយរបស់ព្រះជាម្ចាស់ ដើម្បីអោយអ្នកធ្វើតាមជំរើសនោះបានត្រឹមត្រូវ ។ ប៉ុន្តែអំណាចរបស់មនុស្សលើសជាងពីការជ្រើសរើសប្រព្រឹត្តអំពើអាក្រក់ រឺក៏ ប្រព្រឹត្តអំពើល្អទៅទៀត ។

តើធ្លាប់បានស្តាប់ព័តិមានស្តីពីការសំភាសន៏តារ៉ារត់ប្រណាំងអំពីភាពលំបាកផ្សេងៗ នៃការត្រៀមរៀបចំខ្លួនរបស់គាត់សំរាប់ការប្រកួតបន្ទាប់របស់គាត់ឬទេ? ជួយកាលតារ៉ារត់ប្រណាំងនោះនិយាយអំពីរបួសថ្មីដែលគាត់មានហើយប្រាប់ពីរបួសនោះដែលចាប់ផ្តើមជាបន្តិចម្តងៗ ។ ប៉ុន្តែជារឿយៗ គាត់នឹងនិយាយអំពីរបៀបដែលជាផលវិបាកដើម្បីរៀបចំខាងផ្នែកស្មារតីក្នុងការប្រកួតរបស់គាត់ ។ គាត់ដឹងថា រូបកាយរបស់គាត់មានកំលាំងខ្លាំងល្អ ។ ប៉ុន្តែអំណាចនៃគំនិត! គាត់ត្រូវតែបង្ខំគំនិតរបស់គាត់អោយចេញពីគិតកុំអោយគិតតែផលអវិជ្ជមាន ហើយប្រឹងរូបកាយរបស់គាត់អោយទៅកំរិតមួយ ដែលអាចយកឈ្នះសំរាប់ការប្រកួតនោះ ។ សង្គ្រាមនៃគំនិតជារឿយៗគឺគន្លឹះឆ្ពោះទៅកាន់ជ័យជំនះ មិនមែនអ្នកដែលមានមាឌ និង រូបកាយខ្លាំងនោះទេ ។

អាកប្បកិរិយាដែលអ្នកបង្ហាញក្នុងអំឡុងពេលពេញមួយថ្ងៃ គឺជាសញ្ញាមួយដ៏ច្បាស់ណាស់បង្ហាញទៅកាន់មនុស្សផ្សេងទៀត ទៅកាន់ព្រះជាម្ចាស់ និង មារសាតាំង ។ អាកប្បកិរិយារបស់អ្នកបង្ហាញអំណាចរបស់អ្នក ។ តើចិត្តក្លាហានប៉ុណ្ណា, ការលត់ដំខ្លួនប៉ុណ្ណា, ភាពឆេះឆួលប៉ុណ្ណា, សេចក្តីស្រលាញ់ប៉ុណ្ណា, និង ចិត្តអត់ឲ្យត់ប៉ុណ្ណា ដែលអ្នកមាន? ពាក្យសំដី និង សកម្មភាពរបស់អ្នកបង្ហាញពីការនេះ ។ អ្នកមានអំណាចដើម្បីផ្លាស់ប្តូរការទាំងនេះ ហើយព្រះជាម្ចាស់សព្វព្រះហឫទ័យចាំជួយអ្នក ។ ប៉ុន្តែមានមនុស្សជាច្រើនដែលមិនមែនជាគ្រិសបរិសទ័ បានធ្វើការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងផ្នែកទាំងនេះ ដោយមិនសំឡឹងមើលទៅព្រះជាម្ចាស់សុំជំនួយពីទ្រង់ ។

អំណាចរបស់មនុស្សពិតជាមានដែនកំណត់ច្បាស់លាស់ ។ មនុស្សអាចធ្វើការអស្ចារ្យបាន ដូចដែលសៀវភៅកំណត់ត្រាគីនេសនៅលើពិភពលោកបង្ហាញ ។ ប៉ុន្តែមនុស្សមិនសំដែងការអស្ចារ្យជាលក្ខណៈព្រះជាម្ចាស់បានឡើយ ។ មនុស្សមានដែនកំណត់ចំពោះសមត្ថភាព ដែលព្រះជាម្ចាស់បានបង្កើតមក ។ មានមនុស្សមួយចំនួនបានព្យាយាមធ្វើសកម្មភាពជាលក្ខណៈការអស្ចារ្យដូចព្រះជាម្ចាស់នៅក្នុងកំលាំងរបស់ពួកគេ -- វានឹងមិនដែលកើតឡើងទេ ។ អ្នកអាចបោកបញ្ឆោតមនុស្សអោយជឿថា អ្នកបានសំដែងការអស្ចារ្យដូចជាព្រះ ប៉ុន្តែនៅពេលដែលសេចក្តីពិតត្រូវបានគេដឹង ពេលនោះការបោកបញ្ឆោតនេះកាន់តែច្បាស់ថែមទៀត ។

មានគ្រិស្តបរិសទ័មួយចំនួនមិនបានស្វែងយល់អោយ បានច្បាស់ពីរបៀបដែលព្រះជាម្ចាស់ធ្វើការតាមរយៈមនុស្សដើម្បីសំរេចអោយមានការអស្ចារ្យកើតមាន ។ បេសកជននៃគម្ពីរសញ្ញាថ្មីបានជួបប្រទះនូវបញ្ហានេះផងដែរ ។ មនុស្សបានគិតថា លោកប៉ូលអាចព្យាបាលអ្នកជំងឺបាន ។ ព្រះជាម្ចាស់ពិតជាបានប្រើលោកប៉ូលមែន ប៉ុន្តែអំណាចរបស់ព្រះជា ម្ចាស់បាននាំការព្យាបាលមកកាន់អ្នកជំងឺ មិនមែនអំណាចរបស់លោកប៉ូលទេ ។ (សូមមើល កិច្ចការ ១៤:៨-១៨) ព្រះគម្ពីរព្រមានយើងកុំអោយធ្វើត្រាប់តាមអំណាចនៃការអស្ចារ្យរបស់ព្រះជាម្ចាស់ ឬក៏ ព្យាយាមបង្ខំព្រះជាម្ចាស់អោយសំដែងការអស្ចារ្យ ។ យើងជាអ្នកបំរើរបស់ព្រះជាម្ចាស់ មិនមែនជាចៅហ្វាយរបស់ទ្រង់ទេ ។ យើងមិនមានសេរីភាពប្រាប់អោយព្រះជាម្ចាស់ធ្វើអ្វីដែលទ្រង់ត្រូវតែធ្វើនោះទេ ។ យើងទូលសុំអោយព្រះជាម្ចាស់ធ្វើការអស្ចារ្យ ប៉ុន្តែពេលនោះយើងត្រូវតែយល់ព្រមទទួលយកការសំរេចចិត្តរបស់ទ្រង់ ទៅលើអ្វីដែលនឹងធ្វើវិញ ។

## ខ. ជំនឿ ទល់នឹង ការសន្និដ្ឋាន

ប្រសិនបើអ្នកចង់អោយព្រះជាម្ចាស់ប្រើអ្នក នោះអ្នកត្រូវតែស្វែងយល់នូវអ្វីដែលព្រះជាម្ចាស់ចង់អោយអ្នកធ្វើ និង របៀបដែលទ្រង់អោយវាកើតឡើង ។ មានសោកនាដកម្មជាច្រើនអាចត្រូវបានគេចផុតបាន ប្រសិនបើមនុស្សមានការប្រុងប្រយត្ន័រៀនពីរបៀបដែលព្រះជាម្ចាស់ធ្វើការ ។ យើងអាចមានសន្តិភាព ប្រសិនបើយើងរស់នៅទៅតាមគោលការណ៏ណែនាំដ៏សាមញ្ញនេះ ។ "ព្រះហឫទ័យរបស់ព្រះជាម្ចាស់ត្រូវតែយកទៅសំដែងដោយមនុស្សរបស់ព្រះជាម្ចាស់នៅក្នុងផ្លូវរបស់ទ្រង់ និង នៅចំពេលវេលារបស់ព្រះជាម្ចាស់ផង" ។

មានចំនុចបួនផ្សេងៗពីគ្នា ដែលយើងត្រូវតែច្បាស់ ថាតើយើងចង់អោយព្រះជាម្ចាស់ប្រើយើង ។

១. អ្នកត្រូវតែដឹងនូវអ្វីដែលព្រះជាម្ចាស់ចង់បានកិច្ចការដែលសំរេច

២. អ្នកត្រូវតែដឹង ថាតើអ្នកគឺជាមនុស្សដែលព្រះជាម្ចាស់ចង់ប្រើនៅក្នុងស្ថានភាពនេះមែនឬ

៣.	អ្នកត្រូវតែដឹងនូវអ្វីដែលជាវិធីរបស់ព្រះជាម្ចាស់ដើម្បីបញ្ចប់ការងារនេះ

៤.	អ្នកត្រូវតែដឹងនៅពេលណាដែលព្រះជាម្ចាស់ចង់អោយការងារនេះបានសំរេច

ចំនុចបីក្នុងចំណោមបួននេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ នៅពេលដែលយើងចាប់ផ្តើម ហើយព្យាយាមធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយមិនបានដឹងលក្ខខណ្ឌទាំងបួននេះទេ យើងកំពុងតែស្ថិតនៅក្នុងការប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរនៃការសន្និដ្ឋានរបស់យើង ។

## ការសន្និដ្ឋានគឺជាសកម្មភាពនៃការស្មាន ហើយជាក់ច្បាស់ណាស់ដែលវាដើរវិលងខុសពីគន្លងធម្មតា

ពាក្យថា ការសន្និដ្ឋាននេះត្រូវបានលើកឡើង១១ដងនៅក្នុងព្រះគម្ពីរ ហើយនៅក្នុងករណីនីមួយៗ វាត្រូវបានហៅថាជាអំពើបាប ។ ៩ដងចេញពីពាក្យនេះធ្វើអោយមនុស្សស្លាប់ ។ ពាក្យភាសាហេប្រឺសំរាប់ពាក្យថា អំណួត និងការសន្និដ្ឋានគឺដូចគ្នា ។ អ្នកមិនចាំបាច់អានខគម្ពីរច្រើន ដែលនិយាយពីអំណួត មុនពេលដែលអ្នកដឹងថា ព្រះជាម្ចាស់មានអារម្មណ៍ប៉ុណ្ណាចំពោះអំពើបាបនេះ ។

អ្វីដែលជាសកម្មភាពមួយនៃជំនឿសំរាប់មនុស្សម្នាក់ អាចសកម្មភាពមួយនៃការសន្និដ្ឋានសំរាប់មនុស្សម្នាក់ផ្សេងទៀត ។ យើងមិនអាចស្មានដឹងថា ព្រះជាម្ចាស់ចង់អោយយើងធ្វើនូវកិច្ចការដដែល ដែលទ្រង់បានប្រាប់អោយមនុស្សម្នាក់ផ្សេងទៀតធ្វើនោះទេ ។ ការសន្និដ្ឋានគឺជាអំពើបាប ដែលជំរុញអោយគ្រិស្តបរិសទ័ដែលមានចិត្តក្លាហាន និង ឆេះឆួលដើម្បីបំពេញកិច្ចការអ្វីមួយសំរាប់ព្រះជាម្ចាស់ ។ នៅពេលដែលព្រះយេស៊ូបានស្ថិតនៅក្នុងវាលរហោស្ថាន មារសាតាំងបានមក ហើយ បានល្បួងព្រះយេស៊ូអោយសំដែងការអស្ចារ្យសំរាប់សាច់ឈាមរបស់ទ្រង់ ។

**ម៉ាថាយ ៤:៥-៧**

**ពេលនោះមារនាំព្រះអង្គទៅក្រុងយេរូសាឡឹមជាក្រុងដ៏វិសុទ្ធដាក់ព្រះអង្គលើកំពូល ព្រះវិហារ ហើយពោលថា ប្រសិនបើលោកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន សូមលោតទម្លាក់ខ្លួនចុះទៅក្រោមមើល៍ដ្បិតក្នុងគម្ពីរមានចែងថា ព្រះជាម្ចាស់នឹងបញ្ជាអោយទេវតាចាំទ្រលោក មិនអោយជើងលោកប៉ះទង្គិចនឹងថ្មឡើយ ។ ព្រះយេស៊ូមានព្រះបន្ទូលទៅមារថា ក្នុងគម្ពីរមានចែងទៀតថា កុំល្បងលព្រះជាម្ចាស់ជាព្រះរបស់អ្នកឡើយ ។**

ប្រសិនបើមារសាតាំងអាចធ្វើអោយយើងប្រើប្រាស់ខគម្ពីរមួយ ដោយពុំមានព្រះបន្ទូលពិសេសមកពីព្រះជាម្ចាស់នោះទេ វាអាចបំផ្លាញយើងបាន ។ ប្រសិនបើព្រះយេស៊ូបានធ្វើតាមដំបូន្មានរបស់មារសាតាំង នោះទ្រង់នឹងធ្លាក់ចូលទៅក្នុងអន្ទាក់នៃអំណាចពីការសន្និដ្ឋាន ។ គ្មាននរណាម្នាក់ និង សូម្បីតែព្រះយេស៊ូមានសិទ្ធិប្រាប់ព្រះជាម្ចាស់ពីរបៀប និង នៅពេលណា ដើម្បីប្រើអំណាចនៃការអស្ចារ្យរបស់ទ្រង់ក្នុងការសំដែងការអស្ចារ្យនោះឡើយ ។ ព្រះវរបិតានៅស្ងៀម ហើយព្រះយេស៊ូមិនបានស្មានថា ព្រះជាម្ចាស់ចង់អោយទ្រង់សំដែងការអស្ចារ្យតាមមារនោះទេ ។ ប្រសិនបើព្រះជាម្ចាស់នៅស្ងៀម ពេលនោះអ្នកអាចមានទំនុកចិត្តថា ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យអោយអ្នកធ្វើការនោះទេ ។

ការសន្និដ្ឋានមិនអនុវត្តបាននៅក្នុងគ្រប់ស្ថានភាព ដែលយើងប្រឈមមុខនោះទេ ។ អ្នកមិនចាំបាច់សុំព្រះជាម្ចាស់នៅពេលព្រឹកថា "ឱព្រះជាម្ចាស់អើយ តើទ្រង់ចង់អោយទូលបង្គំចងខ្សែស្បែកជើងរបស់ទ្រង់ឬទេ?" ទ្រង់នឹងប្រហែលជាឆ្លើយតបដោយស្ងៀមស្ងាត់ ។ ដើម្បីចងខ្សែស្បែកជើងបាន មិនតំរូវអោយមានអំណាចនៃការអស្ចារ្យមកពីព្រះជាម្ចាស់នោះទេ ។ ប៉ុន្តែនិយាយថា មាននរណាម្នាក់មកកាន់អ្នក ដែលត្រូវពាក់វ៉ែនតាដើម្បីអាចមើលឃើញ ។ ពួកគេសុំអោយអ្នកអធិស្ឋានសំរាប់ការព្យាបាលដល់ពួកគេ ហើយបន្ទាប់មកពួកគេចង់ដឹងថាតើ ពួកគេគួរតែបោះចោលវ៉ែនតារបស់ពួកគេឬយ៉ាងណា -- គឺដើម្បីបង្ហាញថា ពួកគេមានជំនឿថា ព្រះជាម្ចាស់ព្យាបាលពួកគេ ។ អ្នកត្រូវតែលឺពីព្រះជាម្ចាស់ជាមុនសិន មុនពេលអ្នកប្រាប់ពួកគេអោយចោលវ៉ែនតារបស់ពួកគេ ។

ប្រសិនបើព្រះជាម្ចាស់ស្ងាត់ស្ងៀមនៅក្នុងការឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់អ្នកសំរាប់ ប្រាជ្ញាមកពីព្រះជាម្ចាស់ នោះអ្នកមិនគួរណាស្មានចង់ដឹងថា ព្រះជាម្ចាស់ចង់អោយមនុស្សនោះបោះវ៉ែនតាចោលទេ ។ អ្នកគួរតែលើកទឹកចិត្តពួកគេទៅពិគ្រោះជាមួយវេជ្ជបណ្ឌិតភ្នែក ។ ប្រសិនបើព្រះជាម្ចាស់បានព្យាបាលភ្នែករបស់ពួកគេមែន នោះភស្តុតាងខាងសាច់ឈាមនឹងបង្ហាញថាពិតជាមានការព្យាបាលកើតឡើងមែន ។ មិត្តរបស់អ្នកអាចថ្វាយសេរីរុងរឿងទៅព្រះជាម្ចាស់ ហើយ មានឱកាសដ៏ល្អបំផុតដើម្បីធ្វើទីបន្ទាល់សំរាប់វេជ្ជបណ្ឌិតនោះទៀតផង ។

អំពើបាបនៃការធ្វើការសន្និដ្ឋានកើតឡើង នៅពេលដែលយើងយកព្រះបន្ទូលសន្យាជាទូទៅនៅក្នុងព្រះគម្ពីរ ហើយអនុវត្តវានៅក្នុងស្ថានភាពពិសេសមួយ ដែលព្រះជាម្ចាស់មិនបានមានព្រះបន្ទូលទាល់តែសោះ ។ នៅក្នុង ២ ពង្សាវតារក្សត្រជំពូក៥និយាយពីលោកណាម៉ាន់ ដែលជាបុរសម្នាក់កើតជំងឺឃ្លង់ ហើយបានមកកាន់ព្យាការីអេលីយ៉ា ។ ព្រះជាម្ចាស់បានមានព្រះបន្ទូលមកកាន់លោកអេលីយ៉ាថា ហើយប្រទានការណែនាំមួយចំនួនស្តីពីរបៀបដែលលោក

ណាម៉ាន់អាចទទួលបានការព្យាបាល ។ លោកណាម៉ាន់ត្រូវទៅកាន់ទន្លេយ័ដាន់ដែលមានផុកជាច្រើន ហើយត្រូវ ជ្រមុជខ្លួនរបស់គាត់៧ដងទៅក្នុងទន្លេនោះ ។ លោកក៏បានធ្វើតាមណែនាំទាំងនោះ ហើយព្រះជាម្ចាស់ក៏បានព្យាបាលលោក ។

មានខគម្ពីរជាច្រើនដែលលើកទឹកចិត្តយើងអោយអធិស្ឋានសុំការព្យាបាល ។ ប៉ុន្តែគ្មានខគម្ពីរណាមួយដែលសន្យាយ៉ាងជាក់លាក់ថា អ្នកនឹងទទួលបានការព្យាបាលដោយស្វ័យប្រវត្ត ប្រសិនបើអ្នកធ្វើតាមចំនុចទីមួយៗនៃសកម្មភាពនៅក្នុងតារាង ។ នៅក្នុងគ្រប់ករណីណាក៏ដោយ យើងត្រូវតែពឹងផ្អែកលើព្រះជាម្ចាស់ ដើម្បីដឹកនាំអ្នកទៅនឹងអ្វីដែលទ្រង់ចង់ធ្វើនៅក្នុងស្ថានភាពដ៏ពិសេសនោះ ។

នៅក្នុងព្រះគម្ពីរមានក្រិត្យវិន័យ និង សេចក្តីបង្រៀនជាច្រើនត្រូវបានផ្តល់អោយ ។ យើងមិនចាំបាច់រងចាំសំរាប់ព្រះបន្ទូលមកពីព្រះជាម្ចាស់មុនពេលយើងធ្វើការនោះទេ ។ ឧទាហរណ៍ ក្រិត្យវិន័យទាំងដប់ប្រការផ្តល់នូវសេចក្តីបង្រៀនយ៉ាងជាក់លាក់អ្វីដែលគួរធ្វើ និង អ្វីដែលមិនគួរធ្វើ ។ វានឹងមិនដែលជាបំណងព្រះហឫទ័យអោយអ្នកប្រព្រឹត្តអំពើផិតក្បត់នោះទេ ។ ប៉ុន្តែវាតែងតែជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់អោយអ្នកលើកកិត្តិយស និង គោរពមាតាបិតារបស់អ្នក ។ ដើម្បីស្តាប់បង្គាប់សេចក្តីបង្រៀនទាំងនេះដោយគ្មានព្រះបន្ទូលពិសេសណាមួយមកពីព្រះជាម្ចាស់នោះមិនមែនជាការសន្និដានទេ ។ ដើម្បីនិយាយថា "ខ្ញុំទទួលបានព្រះបន្ទូលពីព្រះជាម្ចាស់អំពីអ្វីដែលត្រូវធ្វើនៅក្នុងស្ថានភាពនេះ" នៅពេលដែលអ្នកមិនបានលឺពីព្រះជាម្ចាស់ទេ ហើយសំដែងជាការអស្ចារ្យដោយគ្រាន់តែសន្និដ្ឋាននោះនាំអ្នកទៅប្រព្រឹត្តអំពើបាបហើយ ។

## គ. កំហុសឆ្គងនៅក្នុងជំនឿពីការបង្រៀននៅសព្វថ្ងៃនេះ

វាជាការគួរអោយក្រៀមក្រម ដែលឃើញថា សេចក្តីបង្រៀនស្តីពីជំនឿបានក្លាយជាបញ្ហាក្តៅនៅតាមក្រុមជំនុំមួយចំនួនសព្វថ្ងៃនេះ ។ គ្រិស្តបរិសទ័ជាច្រើនបានឈ្លោះប្រកែកគ្នា ហើយក្រុមជំនុំជាច្រើនក៏បានបែកបាក់គ្នាដោយព្រោះការមិនចុះសំរុងគ្នាទៅលើអ្វី ដែលព្រះគម្ពីរបង្រៀនស្តីពីសេចក្តីជំនឿ ។

មានបញ្ហាមួយចំនួនជុំវិញការឈ្លោះប្រកែកគ្នានេះ ហើយយើងមិនអាចបំបែកមនុស្សជាពីរក្រុមបានទេ -- អស់អ្នកដែលជឿនៅក្នុងសេចក្តីជំនឿ និងអ្នកផ្សេងទៀតមិនមានជំនឿទៅលើ ។ នៅក្នុងផ្នែកមួយនៃមេរៀននេះ យើងចង់ចំណាយពេលសិក្សាទៅលើបញ្ហាមួយចំនួន ដែលជាចំនុចកណ្តាលនៃការឈ្លោះប្រកែកគ្នានេះ ។ គោលគំនិតនៃអ្នកនិពន្ធនឹងបង្ហាញច្បាស់ណាស់ ចំពោះនរណាម្នាក់ដែលមានជំនឿខ្លាំងនៅលើបញ្ហានេះ ។

## ១.  តើមានភាពខុសគ្នារវាងជំនឿ និង ការជឿដែរឬទេ?

មានមនុស្សខ្លះបង្រៀនថា ពាក្យទាំងពីរនេះត្រូវបានគេប្រើដោយមានការផ្លាស់ប្តូរគ្នាទៅវិញទៅមកតាមរយៈគម្ពីរសញ្ញាថ្មី ។ មុនពេលអ្នកព្យាយាមដោះស្រាយបញ្ហានេះ អ្នកចាំបាច់ត្រូវតែព្យាយាមស្វែងរករបៀបដែលអ្នកបកស្រាយពីន័យនៃពាក្យទាំងពីរនេះ ។ ប្រសិនបើអ្នកមិនអាចយល់ព្រមទៅលើអត្ថន័យនៃពាក្យទាំងពីរនេះទេ ដូច្នេះត្រូវរក្សាខ្យល់ដង្ហើមរបស់អ្នក ហើយការពារមិនអោយមានការឈ្លោះប្រកែកគ្នាឥតប្រយោជន៍នោះទេ ។

យោងតាមនិយមន័យដ៏ប្រយត្ន័ប្រយែងមួយនៃជំនឿដែលបានផ្តល់អោយពីខាងដើមនៅក្នុងសៀវភៅនេះ ខ្ញុំមើលឃើញពាក្យទាំងពីរនេះមានភាពផ្សេងគ្នា ។ ខ្ញុំអាចជឿអ្វីមួយដោយគ្មានការធ្វើអ្វីមួយអំពីគោលជំនឿរបស់នោះបានឡើយ ។ យ៉ាកុប ២:១៤-២៦ ចង្អុលបង្ហាញពីតម្រូវការថា អោយដាក់ជំនឿរបស់អ្នកទាំងមានសកម្មភាពផង ។ នៅពេលណាក៏ដោយ ព្រះយេស៊ូបាននិយាយអំពីជំនឿ រឺក៏បានមានបន្ទូលថា នរណាម្នាក់មានជំនឿ ទ្រង់តែងតែបានធ្វើការនេះគឺថាការអស្ចារ្យបានកើតឡើង ។ សកម្មភាពតែងតែទៅស្របគ្នាជាមួយនឹងជំនឿ ។

ព្រះយេស៊ូមិនបានប្រាប់មនុស្សមានជំងឺថា "អ្នកបានជាហើយ ។ យើងទាំងអស់គ្នាអាចមើលឃើញរោគសញ្ញានៃជំងឺរបស់អ្នក ដែលនៅតែមានជាប់នឹងអ្នក ។ ប៉ុន្តែបន្តជឿ ហើយរោគសញ្ញានោះនឹងចាកចេញពីអ្នក ។ អ្នកបានជាហើយ" ។ ទេ, វិធីរបស់ព្រះជាម្ចាស់គឺតែងតែស្របគ្នាទៅនឹងភាពពិតប្រាកដ ។ ប្រសិនបើភ្នែកនៅតែងងឹត ពេលនោះមនុស្សនោះមិនបានទទួលការព្យាបាលនៅឡើយទេ ។

ខ្ញុំអាចជឿថា ព្រះជាម្ចាស់អាចព្យាបាលនរណាម្នាក់ ប៉ុន្តែនៅពេលជាមួយគ្នាដដែលមិនមានជំនឿ -- អំណាចមកពីព្រះជាម្ចាស់ -- ដើម្បីសំរេចការព្យាបាល ។ ខ្ញុំជឿជាក់ថា ជំនឿរបស់ព្រះជាម្ចាស់ត្រូវបានប្រទានអោយដល់អស់អ្នកដែលជឿ មិនមែនជាការធម្មតាដោយព្រោះពួកគេជឿនោះទេ ប៉ុន្តែដោយព្រោះនៅក្នុងស្ថានភាពដ៏ជាក់លាក់នោះផងដែរ ព្រះជាម្ចាស់ចង់ប្រើអំណាចរបស់ទ្រង់ដើម្បីនាំសេរីរុងមកកាន់អង្គទ្រង់ ។

## ២.  ពាក្យជំនឿត្រូវបានភ្ជាប់ទៅក្នុងចំណេះដឹងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់

មនុស្សខ្លះបង្រៀនថា អ្នកត្រូវតែស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីអោយអ្នកអាចអនុវត្តជំនឿ ។ នៅក្នុងវិធីមួយទូទៅ នោះគឺជាការពិតជាច្រើនលើច្រើនសារ ។ យ៉ាងណាក៏ដោយ មនុស្សខ្លះបង្រៀនថា ប្រសិនបើអ្នក

ស្គាល់ពាក្យដ៏ត្រឹមត្រូវក្នុងការនិយាយ នោះព្រះជាម្ចាស់នឹងធ្វើអ្វីដែលអ្នកប្រាប់ទ្រង់អោយធ្វើ ។ បញ្ហានៅត្រង់នេះគឺថា របៀបដែលពួកគេប្រើអត្ថបទខគម្ពីរ ។ ខគម្ពីរជាច្រើននៅក្នុងព្រះគម្ពីរមិនអាចត្រូវបានគេប្រើដូចជាការសូត្ររបស់គ្រូមន្តអាគមន៍ដើម្បីសំរេចនូវការអស្ចារ្យបាននោះទេ ។ ពន្ធកិច្ចរបស់ព្រះយេស៊ូគឺជាឧទាហរណ៍យ៉ាងច្បាស់ពីការនេះ ។ ជារៀងរាល់ពេល ទ្រង់មិនបានដកស្រង់ខគម្ពីរផ្សេងៗនៅក្នុងគម្ពីរសញ្ញាចាស់ ដើម្បីព្យាបាលនរណាម្នាក់នោះទេ ។ ទ្រង់កម្រធ្លាប់បានប្រើពាក្យដូចគ្នា នៅពេលធ្វើការព្យាបាលមនុស្សនៅក្នុងពេលវេលាផ្សេងៗពីគ្នា ។

យើងមិនអាចយកខគម្ពីរមួយ ហើយនិយាយថា ព្រះជាម្ចាស់ត្រូវតែធ្វើការនេះ ដោយព្រោះវាបានចែងនៅក្នុងព្រះគម្ពីរ ហើយព្រះជាម្ចាស់មិននិយាយកុហកទេ ។ យើងត្រូវតែចងចាំថា គ្រប់ខគម្ពីរនៅក្នុងព្រះគម្ពីរមានលក្ខណៈស្របគ្នាទាំងស្រុងទៅនឹងព្រះគម្ពីរទាំងមូល ។ ខគម្ពីរនីមួយៗត្រូវបានពន្យល់ដោយខគម្ពីរផ្សេងទៀត ។ តុល្យាភាពគឺជាគន្លឹះ ។ ព្រះយេស៊ូបានបង្ហាញការនេះនៅរបៀបដែលទ្រង់បានឆ្លើយតប នៅពេលដែលមារសាតាំងបានដកស្រង់អត្ថបទខគម្ពីរដាក់ទ្រង់ ។

## ៣. តើអ្វីទៅជាសកម្មភាពជំនឿ?

មានមនុស្សខ្លះបង្រៀនថា ជំនឿគឺគ្មានអ្វីច្រើនជាងការសារភាពនូវអ្វី ដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែង ។ ប្រសិនបើអ្នកនិយាយឡើងវិញនូវពាក្យមកពីព្រះគម្ពីរ នោះអ្នកនឹងទទួលបាននូវអ្វីដែលអ្នកនិយាយ ។ ការនេះជួនកាលត្រូវបានគេហៅថា ការសារភាពបែបវិជ្ជមាន ។ ជារឿយៗការនេះការត្រូវបានរំលោភបំពាន ។ មានគ្រិសបរិសទ័ថ្មីដែលមានកំពស់ទាបម្នាក់ត្រូវបានគេលឺ នៅពេលដែលគាត់ដើរត្រង់កន្លែងថ្វាយបង្គំ ដោយនិយាយដដែលៗថា "ខ្ញុំមានកំពស់៦ម៉ែត្រ, ខ្ញុំមានកំពស់៦ម៉ែត្រ ។ " ជំនឿរបស់ព្រះជាម្ចាស់ និង ព្រះគម្ពីរមិនបានបង្រៀនពីការនេះទេ ។ អ្នកមិនអាចនិយាយព្រះបន្ទូលសន្យាដដែលៗចេញពីព្រះគម្ពីរ ហើយអ្នកពិតជាទទួលបាននូវអ្វីដែលអ្នកទូលសុំនោះដោយស្វ័យប្រវត្តបានឡើយ ។ ព្រះជាម្ចាស់គឺជាអ្នកប្រទានអោយនូវអំណាចខាងវិញ្ញាណ និង ការអស្ចារ្យ ។ ការនិយាយព្រះបន្ទូលដដែលៗសារឡើងវិញចេញពីព្រះគម្ពីរ នឹងមិនដែលជំនួសព្រះជាម្ចាស់ និង ផ្នែកផ្ទាល់ខ្លួន ដែលទ្រង់ចង់អោយមាននៅក្នុងសេចក្តីអធិស្ឋាន និង តម្រូវការរបស់យើងម្នាក់ៗនោះបានទេ ។

ការប្រកាសបែបវិជ្ជមានពិតជាមានកន្លែងមួយពិតប្រាកដនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីសំដែងការអស្ចារ្យ ។ មានពេលមួយ នៅពេលដែលព្រះយេស៊ូបានយាងត្រឡប់ទៅកាន់ភូមិកំណើតរបស់ទ្រង់វិញ ទ្រង់មិនធ្វើការអស្ចារ្យអ្វីណាមួយបានឡើយ ដោយព្រោះភាពអជំនឿរបស់ពួកអ្នកភូមិនៅទីនោះ ។ (សូមមើល ម៉ាកុស ៦:១-៦

មនុស្សដែលព្រះយេស៊ូបានព្យាបាលបានមកកាន់ទ្រង់ ហើយសុំជំនួយពីទ្រង់ ។ មានមនុស្សជាច្រើនបានប្រកាសថា ទ្រង់ពិតជាអាចព្យាបាលពួកគេបាន ។ គំរូមើលទៅហាក់ដូចជាច្បាស់ណាស់នៅក្នុងអត្ថបទគម្ពីរ ។ ព្រះជាម្ចាស់មិនចង់បង្ខំជំនួយរបស់ទ្រង់ទៅលើនរណាម្នាក់ ដែលមិនត្រូវវានោះទេ ។

## ៤. ចិត្តសង្ស័យ និង ការប្រកាសបែបអវិជ្ជមាន

តើចិត្តសង្ស័យគឺជាមូលហេតុដ៏ចំបង ដែលធ្វើអោយយើងមិនអាចទទួលបាននូវអ្វីដែលយើងទូលសុំនោះឬយ៉ាងណា? ប្រហែលជានោះគឺជាហេតុមួយនៅក្នុងពេលវេលាខ្លះ ប៉ុន្តែនោះមិនមែនជារឿងរាល់ពេលទេ ។ យ៉ាកុប ១:៦-៨ ផ្តល់នូវសារដ៏ច្បាស់ថា ជួនកាលភាពអជំនឿបញ្ឈប់មនុស្សម្នាក់មិនអោយទទួលបានចំលើយពីព្រះជាម្ចាស់ ។ យ៉ាងណាក៏ដោយ នៅក្នុងម៉ាកុស ៩:១៤-២៩ បុរសម្នាក់បានមកកាន់ព្រះយេស៊ូ ដោយសារភាពថា គាត់មានភាពអជំនឿនៅក្នុងគាត់ (សូមមើល២២៤) ។ ប៉ុន្តែគាត់បានសុំអោយព្រះយេស៊ូជួយគាត់ជាមួយនឹងភាពអជំនឿរបស់គាត់ ហើយសុំអោយទ្រង់ព្យាបាលកូនប្រុសរបស់គាត់ ។ ព្រះយេស៊ូពិតជាបានឆ្លើយតបទៅនឹងការអធិស្ឋានរបស់គាត់ បើទោះជាឪពុកមានចិត្តសង្ស័យក៏ដោយ ។

ព្រះជាម្ចាស់គឺតួនៃសេចក្តីស្រលាញ់ និង ជាព្រះពេញទៅដោយចិត្តសប្បុរស ។ ទ្រង់ពិតមានការខ្វល់ខ្វាយពីយើង ទោះបីជាយើងមិនបានល្អឥតខ្ចោះនៅក្នុងសេចក្តីជំនឿរបស់យើងក៏ដោយ ។

មានមនុស្សជាច្រើនបានអធិស្ឋានដោយមានទំនុកចិត្តយ៉ាងខ្លាំង ប៉ុន្តែមិនបានឃើញព្រះជាម្ចាស់សំដែងព្រះបារមីទេ ។ យ៉ាកុប ៤:៣ ចែងថា "ហើយនៅពេលដែលអ្នករាល់គ្នាទូលសុំ អ្នករាល់គ្នាមិនបានទទួលវា ដោយព្រោះអ្នករាល់គ្នាមានបំណងអាក្រក់ ដ្បិតអ្នករាល់គ្នាបានទូលសុំសំរាប់តែប្រយោជន៏សប្បាយខាងសាច់ឈាមរបស់អ្នករាល់គ្នា ។" ចិត្តសង្ស័យមិនមែនជាមូលហេតុសំរាប់ការអធិស្ឋានដែលមិនបានឆ្លើយតបទាំងនេះទេ ប៉ុន្តែបញ្ហានៅត្រង់ការដែលមានបំណងអាក្រក់វិញ ។

មានខ្លះបង្រៀនថា អ្នកត្រូវតែប្រុងប្រយត្ន័ចំពោះការប្រកាសបែបអវិជ្ជមាន ។ ប្រសិនបើអ្នកធ្វើវា ការនោះនឹងអោយមារសាតាំងកន្លែងដាក់ជើង ដើម្បីបំផ្លាញការល្អៗដែលព្រះជាម្ចាស់អាចធ្វើសំរាប់អ្នក ។ បញ្ហាជាមួយនឹងការបង្រៀននេះគឺថា វាមានមួយចំណែកពិតជាត្រឹមត្រូវ ប្រសិនបើការប្រកាសបែបអវិជ្ជមានរបស់អ្នកពិពណ៌នាយ៉ាងច្បាស់លាស់នូវអ្វីដែលអ្នកជឿអំពីស្ថានភាពនោះ ដូច្នេះមិនត្រូវភ្ញាក់ផ្អើលឡើយ នៅពេលទ្រង់មិនធ្វើអ្វីទាំងអស់ ។

ប៉ុន្តែមានមនុស្សខ្លះប្រើគោលគំនិតនេះស៊ីជំរៅជាងនេះទៅទៀត ។ ពួកគេនិយាយថា "កុំអោយប្រកាសថាអ្នកមានជំងឺផ្តាសាយ ឡើយ" ប្រសិនបើអ្នកប្រកាសបែបនេះ នោះអ្នកនឹងមានជំងឺនេះមែន ។ ជីវិតរបស់គ្រិស្តមិនមែនធ្លាក់ចុះ រឺក៏ ងើបឡើងដោយការនិយាយពាក្យពិសេសទាំងនេះទេ ។ ជីវិតរបស់យើងនៅក្នុងអង្គព្រះយេស៊ូគ្រិស្ត មិនមែននៅក្នុងការសូត្របែបសាសនាទេ ។ ទំនាក់ទំនងរបស់យើងជាមួយព្រះគ្រិស្តផ្អែកទៅលើសេចក្តីស្រលាញ់ និង ការទុកចិត្តរបស់យើងនៅក្នុងអង្គទ្រង់ ។

នៅក្នុងយ៉ូហាន ១៦:១៣ តើព្រះយេស៊ូបាន "ប្រកាសពាក្យបែបអវិជ្ជមាន" ដោយសន្យាថា ការរងទុក្ខលំបាក និង បញ្ហាផ្សេងៗនឹងកើតមានចំពោះអ្នកដើរតាមទ្រង់? តើព្រះយេស៊ូបាន "ប្រកាសពាក្យបែបអវិជ្ជមាន" ទៅលើលោកពេត្រុស នៅពេលដែលទ្រង់មានបន្ទូលថា លោកពេត្រុសនឹងបដិសេធន៏ទ្រង់បីដងនៅយប់នេះ មុនពេលគេឆ្កាងទ្រង់? ទេ, ព្រះយេស៊ូគ្រាន់តែបានប្រាប់ថា វានឹងកើតមានឡើងមែន ។ ប្រសិនបើអ្នកឈឺ ហើយមានគ្រុនក្តៅប្រកាសវា ឬក៏ ទទួលស្គាល់ថា អ្នកពិតជាគ្រុនក្តៅមែន ហើយវានឹងមិនបានប្រសើរវិញ តែអាចអាក្រក់ជាងនេះវិញ ។ គ្រុនក្តៅមានទំនាក់ទំនងទៅបញ្ហាខាងថ្នាំពេទ្យ -- គ្រាន់តែជាពាក្យប៉ុណ្ណោះមិនអាចធ្វើអោយអ្នកកើតមានជំងឺគ្រុនក្តៅនោះបានទេ ។

## ៥. តើការប្រើប្រាស់ថ្នាំពេទ្យជាការខុសឆ្គងឬយ៉ាងណា?

អស់អ្នកដែលបង្រៀនថា ថ្នាំពេទ្យ និង ជំនឿមិនចុះសម្រុងគ្នាទេ នោះពិតជាមិនទាន់យល់ព្រះគម្ពីរបានល្អប៉ុន្មានទេ ។ តើខគម្ពីរនៅត្រង់កន្លែងណាខ្លះ ដែលនិយាយថាគ្រិស្តបរិសទ័មិនគួរប្រើប្រាស់ថ្នាំពេទ្យទេ រឺក៏ថា គ្រប់វេជ្ជបណ្ឌិតទាំងអស់សុទ្ធតែជាឧបករណ៏របស់មារសាតាំង? គ្រប់អ្វីៗដែលល្អសុទ្ធតែមកពីព្រះជាម្ចាស់ទាំងអស់ ។ ព្រះជាម្ចាស់បានបង្កើតទាំងរូបកាយរបស់យើង និង សារធាតុគីមី ដែលវាចូលទៅធ្វើអោយបង្កើតទៅថ្នាំ ។ ទ្រង់ស្រលាញ់យើង និង ចង់អោយយើងសប្បាយរីករាយនៅក្នុងជីវិតនេះនៅលើផែនដីនេះ ។ ព្រះជាម្ចាស់ប្រើប្រាស់ថ្នាំពេទ្យជាច្រើនដង ។ នៅក្នុងគម្ពីរសញ្ញាចាស់មានទៅដោយក្រឹត្យវិន័យជាច្រើនដែលទាក់ទងទៅនឹងថ្នាំពេទ្យសំរាប់សាសន៏យូដា ។ សៀវភៅដែលមានចំណងជើងថា <u>គ្មានជំងឺណាមួយឡើយ</u> រៀបរៀងឡើងដោយ វេជ្ជបណ្ឌិត អេ អាយ ម៉ាក់មីឡេន ដែលបង្ហាញ របៀបដែលក្រឹត្យវិន័យនៅក្នុងព្រះគម្ពីរស្តីពីថ្នាំពេទ្យស្របតាមសេចក្តីពិតខាងវិជ្ជសាស្ត្រ ដែលត្រូវបានគេរកឃើញនាសព្វថ្ងៃនេះ ។

អ្នកសរសេរព្រះគម្ពីរដំណឹងល្អលូកា គឺជាវិជ្ជបណ្ឌិត ។ នាពេលសព្វថ្ងៃនេះ មានវេជ្ជបណ្ឌិតជាច្រើនដែលជាគ្រិស្តបរិស័ទដ៏ពិត ។ ព្រះជាម្ចាស់អាចប្រើពួកគេបាន ប្រសិនបើទ្រង់ជ្រើសរើសពួកគេ រីក៏ ព្រះជាម្ចាស់អាចព្យាបាលនរណាម្នាក់អោយបានជាភ្លាម១ ។ គ្មានអត្ថបទខគម្ពីរណាមួយ ដែលបញ្ឈប់គ្រិស្តបរិសទ័មិនអោយប្រើប្រាស់ថ្នាំពេទ្យនោះទេ ។ នៅពេលដែលព្រះយេស៊ូបានព្យាបាលបុរសកើតឃ្លង់ម្នាក់ ទ្រង់បានប្រាប់បុរសនោះអោយទៅបង្ហាញខ្លួនដល់ពួកបូជាចារ្យ ។ ការនេះបានបង្ហាញថា ព្រះយេស៊ូបានផ្តល់កិត្តិយសក្រឹត្យវិន័យនៅក្នុងគម្ពីរសញ្ញាចាស់ស្តីពីថ្នាំពេទ្យដែលនៅតែមានប្រសិទ្ធិភាពមកទល់សព្វថ្ងៃនេះ ។

## ៦. តើព្រះជាម្ចាស់មានការលោតចុះឡើងនៅក្នុងព្រះគម្ពីរឬទេ?

មានមនុស្សមួយចំនួនដែលបង្រៀនថា ព្រះជាម្ចាស់មានការលោតចុះឡើងនៅក្នុងព្រះគម្ពីរ ។ "ប្រសិនបើទ្រង់បានមានបន្ទូលវានៅក្នុងព្រះគម្ពីរ នោះទ្រង់ត្រូវតែការនោះសំរាប់អ្នក ។" បញ្ហាដ៏ធំបំផុតជាមួយនឹងការបង្រៀននេះគឺថា វាធ្វើអោយបរាជ័យក្នុងការទទួលស្គាល់ថា ព្រះជាម្ចាស់ជានរណា ។ ទ្រង់មិនមែនជាអ្នកក្មេងប្រុសរបស់អ្នកដើម្បីអោយបញ្ជាតាមតែចិត្តនោះទេ ។ ទ្រង់គឺជាព្រះជាម្ចាស់ អ្នកដែលបង្កើតពិភពលោកនេះ ។

ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយវាជាព្រះបន្ទូលពិត ។ ប៉ុន្តែយើងត្រូវប្រុងប្រយត្ន័ថា យើងអនុវត្តព្រះបន្ទូលអោយបានត្រឹមត្រូវនៅក្នុងជីវិតរបស់យើង ។ ព្រះគម្ពីរមិនអាចត្រួតត្រាលើព្រះជាម្ចាស់បានទេ ។ ព្រះជាម្ចាស់នឹងមិនអនុញ្ញាត្តិអោយអង្គទ្រង់ស្ថិតនៅក្នុងប្រអប់មួយ ដែលអ្នកអាចនិយាយថា "នេះគឺជាអ្វីដែលព្រះជាម្ចាស់នឹងធ្វើជារៀងរាល់ពេល" ។ ព្រះជាម្ចាស់មានសេរីភាពក្នុងមានឥទ្ធិពលទៅលើមនុស្សនៅក្នុងវិធីមួយ ដែលទ្រង់ចង់ធ្វើការនោះ ។ ការងាររបស់យើងគឺមិនមែនប្រាប់ព្រះជាម្ចាស់នូវអ្វីត្រូវធ្វើ ប៉ុន្តែផ្ទុយមកវិញត្រូវធ្វើដែលទ្រង់ចង់អោយយើងធ្វើ ។

ស្ថានភាពណាក៏ដោយដែលអ្នកជួបប្រទះ ត្រូវមានទំនុកចិត្តថា ព្រះជាម្ចាស់ពិតជាមានការខ្វល់ខ្វាយពីមែន ។ ទ្រង់បានសន្យាថាគង់នៅជាមួយអ្នក ។ ទ្រង់នឹងប្រទានអំណាចដល់អ្នក ដើម្បីអោយអ្នកប្រើអំណាចនោះរស់នៅសំរាប់ទ្រង់ ។

មានពេលជាច្រើនដែលព្រះជាម្ចាស់នឹងប្រើអំណាចនៃការអស្ចារ្យរបស់ទ្រង់ ។ ប្រហែលជាអ្នកនឹងអាចស្ថិតនៅក្នុងការអស្ចារ្យមួយក្នុងចំណោមនៃការអស្ចារ្យផ្សេងទៀតរបស់ទ្រង់ ។ ទោះបើជាករណីណាក៏ដោយ ផ្តោតចំណាប់អារម្មណ៏របស់អ្នកទៅលើការខិតទៅជិតរកព្រះជាម្ចាស់ ។ សេចក្តីស្រលាញ់របស់អ្នកសំរាប់ទ្រង់គឺជាផ្នែកមួយដ៏សំខាន់បំផុតនៃជីវិតរបស់អ្នក ។